■ ត្រួអប់រំជំនឿ២មណ្ឌលសកម្មភាព
ទទួលមេរៀនអប់រំជំនឿបន្ថែម <ទំព័រៈ ១៥

■ អភិបាលភូមិភាគបាត់ដំបង លោក អេនរីគេ ហ្វីកាបេដ្ឋ
ទទួលពានរង្វាន់ «Gijónes of the Year» <ទំព័រៈ ១៦



កាសែតចេញផ្សាយ
ប្រចាំខែ ឆ្នាំទី១៣

# អ្នកនាំសារ
# the messenger

ខែ កក្កដា | ឆ្នាំ ២០២៣ | លេខទី ១៥៨

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

July, 2023 | #158

## យុវជនកម្ពុជាចូលរួមទិវាយុវជនពិភពលោកនៅព័រទុយហ្គាល់




ព្រះសហគមន៍នៅប្រទេសកម្ពុជាមានយុវជន បព្វជិត-ជិតា និងលោកអភិបាលសរុប៤៥នាក់ បានទៅចូលរួម
ទិវាយុវជនពិភពលោកនៅព័រទុយហ្គាល់ផងដែរ កាលពីថ្ងៃទី២៥ ខែកក្កដា ដល់ថ្ងៃទី៨ ខែសីហាកន្លងទៅ។
ទិវាយុវជនពិភពលោកលើកនេះមានយុវជនចូលរួមប្រមាណ១លាន៥សែននាក់ ដែលមកពីជាង១៩០ប្រទេស។
គេក៏សង្កេតឃើញថា ក្នុងទិវាមិនមែនមានតែគ្រីស្តបរិស័ទកាតូលិកចូលរួមប៉ុណ្ណោះទេ
ក្នុងនោះក៏មានយុវជនជាច្រើននិកាយផ្សេងទៀតបានចូលរួមផងដែរ។
ទិវាយុវជនពិភពលោកលើកទី៣៨នឹងប្រព្រឹត្តទៅនៅឆ្នាំ២០២៧នៅឯប្រទេសកូរ៉េខាងត្បូង។

រឿងពេញទំព័រទី១៨-១៩

# ការផ្លាស់ប្តូរអំណាច ក្នុងទំព័រប្រវត្តិសាស្ត្រនៅកម្ពុជា



ថ្មីៗនេះក្រោយការប្រកាសលទ្ធផល នៃការរាប់សន្លឹកឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៧ ដែលគណបក្សប្រជាជនបានទទួលសំឡេងគាំទ្រពីប្រជាពលរដ្ឋច្រើនជាងគេបំផុត។ តាមលទ្ធផលនេះ មានន័យថាគណបក្សប្រជាជនកម្ពុជា បន្តដឹកនាំរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបន្តទៅទៀត។

គណបក្សនេះ បានទទួលការគាំទ្រពីប្រជាជន និងបានដឹកនាំប្រទេសកម្ពុជា ចាប់តាំងពីការបោះឆ្នោតដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ ហៅកាត់ថាអ៊ុនតាក់ ១៩៩៣ ។ នេះដោយមិនរាប់បញ្ចូល ការដឹកនាំប្រទេសកម្ពុជា ក្រោយគណបក្សប្រជាជនកម្ពុជានេះ បានផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុលពត ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រហូតដល់ថ្ងៃដែលអ៊ុនតាក់បានរៀបចំការបោះឆ្នោត។

សម្តេចតេជោ ហ៊ុន សែន ដែលសព្វថ្ងៃជាប្រធានគណបក្សប្រជាជនកម្ពុជា ក្លាយជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាកម្ពុជាតាំងពីឆ្នាំ១៩៨៥ រហូតមកដល់ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៣នេះ។ សម្រាប់អាណត្តិទី៧ សម្តេចតេជោ ហ៊ុន សែន ប្រធានគណបក្សប្រជាជនកម្ពុជា បានសម្រេចផ្ទេរអំណាច តំណែងនាយករដ្ឋមន្ត្រីទៅលោកឧត្តមសេនីយ៍បណ្ឌិត ហ៊ុន ម៉ាណែត ដោយមានគាំទ្រពីសមាជិក សមាជិការគណបក្សប្រជាជនកម្ពុជា ។

ការផ្ទេរអំណាច ដ៏កម្រ បែបនេះ ទៅកាន់អ្នកបន្តវេណ របស់គណបក្សប្រជាជនកម្ពុជា ជាសករាជថ្មីមួយសម្រាប់ទំព័រប្រវត្តិសាស្ត្រកម្ពុជា ។ ព្រោះថា ប្រទេសកម្ពុជា បានឆ្លងកាត់ដំណាក់កាលការផ្ទេរអំណាចប្រកបដោយហឹង្សា និងសង្គ្រាម បង្ហូរឈាមគ្នារាប់រយឆ្នាំមកហើយ។ លើកនេះជាការផ្ទេរអំណាចមួយប្រកបដោយអំណរសប្បាយ សំឡេងហ៊ោរកញ្ជ្រាវ សើចក្អាកក្អាយ ដែលជាពន្លឺថ្មីសម្រាប់ប្រទេសកម្ពុជា ក្នុងការពង្រឹងអំណាចសេដ្ឋកិច្ច និងអភិវឌ្ឍន៍ខ្លួនឲ្យកាន់តែប្រសើរ និងលូតលាស់រុងរឿងពិតប្រាកដ ។

ជាមួយគ្នានេះ មិនត្រឹមតែតំណែងនាយករដ្ឋមន្ត្រីនោះទេ ក្បាលម៉ាស៊ីននៅក្នុងជួររាជរដ្ឋាភិបាល ក៏នឹងរៀបចំឡើងវិញទាំងអស់ដែលក្នុងនោះភាគច្រើនជាកូនចៅ មន្ត្រីជាន់ខ្ពស់ជាសមាជិកគណបក្សប្រជាជន។ យុវជនបន្តវេន សុទ្ធតែជាបញ្ញាជន ដែលបានទទួលការអប់រំខ្ពង់ខ្ពស់ នៅក្រៅប្រទេស នៅក្នុងប្រទេសជឿនលឿនលើលោក ជាធនធានរបស់កម្ពុជាពិតប្រាកដ។

ហេតុនេះ ការផ្ទេរអំណាចដល់អ្នកបន្តវេនជាពន្លឺថ្មីមួយទៀត ជាកំលាំងចលករថ្មីសម្រាប់ដឹកនាំនាវាកម្ពុជា ឲ្យរលូនទៅមុខ ប្រកបដោយសន្តិភាព ការអភិវឌ្ឍរុងរឿង កែសម្រួលប្រព័ន្ធនយោបាយដឹកនាំដែលអសកម្ម លុបបំបាត់បន្តិចម្តងៗអំពើពុករលួយ ការងារគិតតាមខ្សែបណ្តាញ ភាពអយុត្តិធម៌សង្គម ការរើសអើងអ្នកមាននិងអ្នកក្រក្នុងការទទួលសេវាសេវាសាធារណៈ សុខាភិបាល ផ្លូវច្បាប់នានា... កំណែរទម្រង់ប្រព័ន្ធអប់រំឲ្យប្រសើរឡើងថែមទៀត... លើកកម្ពស់ការចូលរួមរបស់ប្រជាជនជាមួយរាជរដ្ឋាភិបាល... លើកកម្ពស់វិស័យកសិឧហ្សាហកម្ម ជំរុញការអភិវឌ្ឍនៅក្នុងសហគមន៍ជាដើម។ល។

យើងសង្ឃឹមថា អ្វីៗនឹងប្រសើរឡើងក្នុងរបត់ថ្មីនៃការដឹកនាំរបស់លោកនាយករដ្ឋមន្ត្រីថ្មី ដោយនាំកម្ពុជាឆ្ពោះទៅរកស្ថិរភាពទាំងនយោបាយ សេដ្ឋកិច្ច និងវប្បធម៌ជាតិ៕

Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក
ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ លេខចុះបញ្ជី២០២២៖ ១២៧៩|២២ឆត.ប្រ
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Contact: (855) 17 726 060
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh

# មិន ចិន្តា៖ ភ្នែកខ្ញុំពិការទាំងពីរមែន ប៉ុន្តែចិត្តខ្ញុំមិនពិការ



*អត្ថបទ៖ អរិយបុត្រ*

នារីពិការភ្នែកទាំងពីរមួយរូប មកពីខេត្តកណ្តាល ជាមន្រ្តីបម្រើការនៅក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន ជានារីពិការភ្នែកកម្ពុជាដំបូងគេដែលមានឱកាសទទួលអាហារូបករណ៍ទៅបន្តការសិក្សាថ្នាក់អនុបណ្ឌិតនៅសាកលវិទ្យាល័យមួយនៅក្នុងប្រទេសអូស្រ្តាលី។

នារីដែលពោរពេញដោយវីរភាពរូបនោះមានឈ្មោះថា មិន ចិន្តា អាយុ ៣៣ ឆ្នាំ បានផ្តល់បទសំភាសន៍តាមបណ្តាញសង្គមដល់យើងខ្ញុំដែលមានអត្ថន័យដូចខាងក្រោម៖

*តើមកដល់ពេលនេះ ចិន្តាកំពុងតែរៀនលើមុខវិជ្ជាអ្វីនៅអូស្រ្តាលី?*

**មិន ចិន្តា៖** ក្រោយពីខ្ញុំបាន បញ្ចប់ការសិក្សាបរិញ្ញាប័ត្រនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ខ្ញុំក៏មានលទ្ធភាព និងត្រូវបានជ្រើសរើសចូលបម្រើការនៅក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន។ សព្វថ្ងៃនេះខ្ញុំ កំពុងសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឬអនុបណ្ឌិតផ្នែកគោលនយោបាយ និងការអនុវត្តនៅសាកលវិទ្យាល័យក្នុងទីក្រុងអាឌីឡេត ប្រទេសអូស្រ្តាលី តាមរយៈអាហារូបករណ៍អូស្រ្តាលី។

ខ្ញុំបានមកដល់ទីក្រុងអាឌីឡេត នេះតាំងតែពីខែមិថុនា ឆ្នាំ២០២២ ហើយគ្រោងនឹងបន្តស្នាក់នៅ និងរៀននៅទីនេះរហូតដល់ប្រហែលជាពាក់កណ្តាលឆ្នាំ២០២៤ខាងមុខ។

*តើចិន្តាជាជនពិការទីមួយ ដែលមានឱកាសទទួលអាហារូបករណ៍មកសិក្សានៅក្រៅប្រទេសបែបនេះមែនទេ?*

**មិន ចិន្តា៖** តាមពិតទៅមានជនពិការជាច្រើនរូបមកហើយដែលមានឱកាសទទួលបានការសិក្សានៅក្រៅប្រទេស ប៉ុន្តែខ្ញុំអាចជាជនពិការភ្នែកទីមួយដែលបានទទួលអាហារូបករណ៍មកបន្តការសិក្សាដល់កម្រិតអនុបណ្ឌិតនៅក្រៅប្រទេស។

*នៅក្នុងនាមជាជនពិការភ្នែក តើចិន្តាជួបការលំបាកយ៉ាងណានៅក្នុងការបន្តការសិក្សានៅក្រៅប្រទេសបែបនេះ?*

**មិន ចិន្តា៖** ជាជនពិការដូចខ្ញុំវាមិនមែនជារឿងងាយស្រួលនៅក្នុងការរៀននោះទេ ប៉ុន្តែខ្ញុំនឹងតស៊ូអត់ធ្មត់ ដើម្បីបញ្ចប់ការសិក្សាឱ្យបាន។ រៀននៅទីនោះសម្រាប់និស្សិតអូស្រ្តាលី និងអ្នកមិនពិការភ្នែកប្រហែលជាមិនពិបាកដូចជាខ្ញុំនោះទេ ប៉ុន្តែសម្រាប់ខ្ញុំ គឺត្រូវប្រឈមមុខច្រើនតាំងពីភាសាអង់គ្លេស បច្ចេកវិទ្យាព័ត៌មានដែលពាក់ព័ន្ធនឹងការរៀន គ្រឹះមូលដ្ឋានកាលពីការសិក្សានៅថ្នាក់បរិញ្ញាប័ត្រដោយសារតែកង្វះឯកសារសម្រាប់ជនពិការ ប៉ុន្តែទោះបីជាយ៉ាងណាក៏មានសេវាគាំទ្រជួយច្រើននៅក្នុងការរៀន។

វាពិតជាលំបាកណាស់ពីព្រោះគេមានភ្នែកទាំងគូគេថា រៀនពិបាកដោយរៀនទាំងថ្ងៃទាំងយប់ ហើយសូម្បីតែពេលចុងសប្តាហ៍ថែមទៀត។ ដូច្នេះខ្ញុំមានតែខំ និងប្តេជ្ញាចិត្តហើយក៏ឆ្លៀតពេលខ្លះមើលថែរក្សាកូនតូចទៀត ដើម្បីឲ្យគេមានសុខភាពល្អទាំងផ្លូវកាយ និងផ្លូវចិត្ត។

*តើចិន្តាត្រូវរៀនជាមួយនឹងជនពិកាទាំងអស់ ឬក៏រៀនចម្រុះគ្នាជាមួយនឹងនិស្សិតទូទៅ?*

**មិន ចិន្តា៖** ខ្ញុំកំពុងតែរៀននៅក្នុងថ្នាក់ជាមួយនឹងជនពិការភ្នែក២នាក់ផ្សេងទៀត ដោយម្នាក់មកពីស្រីលង្ការ និងម្នាក់មកពីឥណ្ឌូនេស៊ី ក្នុងនោះក៏មាននិស្សិតដែលមានកាយសម្បទាគ្រប់គ្រាន់ជាច្រើននាក់ថែមទៀតដែរ។ ខ្ញុំមកទីនេះជាមួយនឹងកូនស្រីម្នាក់ ខណៈស្វាមីខ្ញុំ ដែលជាជនពិការភ្នែកដែរនោះកំពុងតស៊ូខិតខំរៀនភាសាអង់គ្លេស ដើម្បីមកបន្តការសិក្សាជាមួយនឹងខ្ញុំដែរ។





*តើជីវភាពរស់នៅអូស្រ្តាលីយ៉ាងម៉េចដែរនៅពេលនេះ?*

**មិន ចិន្តា៖** ជីវភាពខ្ញុំ នៅអូស្រ្តាលីជាមួយនឹងកូនស្រីមិនអីទេ។ ជីវភាពកំពុងតែទម្លាប់ហើយជនពិការនៅស្រុកគេរស់នៅដោយឯករាជ្យ រីករាយ គេទៅណាក៏បាន ចង់ធ្វើអ្វីក៏បាន ជីវិតរបស់គេល្អមែនទែន។ នៅស្រុកយើងជនពិការភ្នែកដូចជាខ្ញុំគឺធ្ងន់ធ្ងរមិនអាចធ្វើអ្វីបានទេ។ នៅទីនេះគេឱ្យតម្លៃដោយស្មើភាពគ្នា មិនមែនមានន័យថា យើងពិការគួរឱ្យអាណិតទេ គេបង្កលក្ខណៈងាយស្រួលដល់ជនពិការរស់នៅដោយខ្លួនឯង ងាយៗតាំងពីសេវាឡានក្រុង និងជីវភាពរស់នៅគ្រប់បែបគ្រប់យ៉ាង។

ពេលទៅទិញទំនិញគេមានអ្នកផ្តល់សេវាជួយជនពិការដែលគេដឹង គេយល់ពីភារកិច្ចរបស់គេគ្រប់យ៉ាងធ្វើឱ្យជីវិតរបស់គេ រស់នៅដោយមិនមានគំនិតថាខ្លួនរស់នៅជាបន្ទុករបស់នរណាម្នាក់ឡើយ។

*នៅពេលបញ្ចប់ការសិក្សា តើចិន្តាមានបំណងធ្វើអ្វីនៅស្រុកយើង?*

**មិន ចិន្តា៖** ជាមួយនឹងបទពិសោធន៍នៅអូស្រ្តាលី និងចំណេះដឹងពីការរៀន អ្វីដែលខ្ញុំចង់ធ្វើមុនគេ គឺខ្ញុំ ចង់បង្កើតឱ្យមានក្រុមអ្នកផ្តល់សេវាកម្មជួយជនពិការ។ ខ្ញុំចង់ធ្វើវាច្រើនណាស់ ប៉ុន្តែខ្ញុំគិតចំណុចមួយមុនគេ ខ្ញុំនឹងគិតឱ្យស៊ីជម្រៅដើម្បីឱ្យជនពិការភ្នែក និងជនពិការនានាអាចទៅកន្លែងសំខាន់ៗដោយមិនចាំបាច់មានជំនួយពីសាច់ញាតិ ឬក៏នរណាឡើយដូចជាទៅពេទ្យទៅផ្សារជាដើម។

មកនៅទីនេះខ្ញុំមានឯករាជ្យ ពេលទៅស្រុកខ្មែរខ្ញុំនឹងធ្វើអ្វីគ្រប់យ៉ាង ដើម្បីឱ្យជនពិការភ្នែកដូចជាខ្ញុំអាចរស់នៅដោយឯករាជ្យបាន៕

# យុវជនខ្មែរនិយាយអំពីជីវិតស្នេហាមុនរៀបការ

*អត្ថបទ៖ ផល សុផានិត*

នៅក្នុងបរិបទសង្គមខ្មែរ កូនស្រីតែងតែត្រូវបានអាណាព្យាបាលគ្រប់គ្រង និងប្រៀនប្រដៅយ៉ាងតឹងរ៉ឹងជាងកូនប្រុស ដោយហេតុថាមនុស្សស្រីជាភេទទន់ខ្សោយ និងងាយរងគ្រោះទាំងផ្នែករាងកាយ និងស្មារតី។



កូនស្រីជាតំណាងកិត្តិយសមួយដ៏សំខាន់សម្រាប់ក្រុមគ្រួសារខ្មែរ ដូច្នេះការប្រៀនប្រដៅកូនស្រីឱ្យសក្តិសមជាស្ត្រីខ្មែរតែងតែមានការយកចិត្តទុកដាក់យ៉ាងខ្ពស់ពីសង្គមគ្រួសារ។ មានក្បួនច្បាប់ខ្មែរជាច្រើនដែលបានចងក្រងដើម្បីប្រៀនប្រដៅស្ត្រី ហើយក្នុនចំណោមដំបូន្មានទាំងនោះ ការហាមកូនស្រីមានទំនាក់ទំនងផ្លូវភេទមុនពេលរៀបអាពាហ៍ពិពាហ៍ គឺត្រូវបានគេប្រកាន់ខ្ជាប់រហូតមក។

តែទោះជាយ៉ាងនេះក្តី នាពេលបច្ចុប្បន្ននេះ យុវជនយុវតីមួយចំនួនមានភាពក្លាហាន ហើយហ៊ានបើកចំហពីស្នេហារបស់ពួកគេច្រើនជាងមុន។ យុវតីខ្លះហ៊ានសម្រេចចិត្តជ្រើសរើសដៃគូស្នេហា និងបានឈានដល់ការរួមភេទមុនរៀបការជាមួយដៃគូសង្សារទៀតផង ដែលសង្គមខ្មែរយល់ថា «នេះជាការប្រព្រឹត្តិខុសហើយប្រាសចាកទំនៀមទម្លាប់ប្រពៃណីរបស់ខ្លួន»។

ទាក់ទិននឹងបញ្ហានេះ យុវតី ប៉ូវ៉ាន ជានិស្សិតនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ យល់ឃើញថា យុវតីខ្មែរមិនគួររួមរស់ ឬក៏រួមភេទជាមួយដៃគូស្នេហាមុនពេលរៀបការនោះទេ។

កញ្ញាបានថ្លែងថា ៖ «រឿងដែលសំខាន់បំផុតនោះគឺ ស្ត្រីខ្មែរត្រូវប្រកាន់ខ្ជាប់នូវទំនៀមទម្លាប់ប្រពៃណីដ៏ល្អផូរផង់របស់ខ្លួន មិនត្រូវធ្វើតាមវប្បធម៌ទំនៀមទម្លាប់បរទេសនោះទេ។ ទោះបីជាមានមតិខ្លះយល់ឃើញថា ទស្សនៈបែបនេះហួសសម័យក្តី តែត្រង់រឿងរួមរស់ជាមួយគ្នាដោយមិនបានរៀបការ គឺជារឿងមិនអាចទទួលយកបាននៅក្នុងសង្គមខ្មែរ ព្រោះថាវាធ្វើឲ្យបាត់បង់តម្លៃរបស់ស្ត្រីខ្មែរទាំងឡាយ»។

ស្រដៀងគ្នានេះដែរ យុវជន សំណាង ជានិស្សិតច្បាប់ម្នាក់បានបញ្ចេញយោបល់ផងដែរថា រឿងរស់នៅជាមួយគ្នារវាងមនុស្សស្រី និងប្រុសទាំងមិនបានរៀបការតាមប្រពៃណីគឺជាការមិនត្រឹមត្រូវសោះឡើយ ទោះបីពួកគេជាគូសង្សារនឹងគ្នាក្តី។

សំណាងសង្កត់ធ្ងន់ថា ៖ «ប្រពៃណីខ្មែរមានតំណមយ៉ាងតឹងរ៉ឹងខ្លាំងចំពោះកូនស្រី ហើយពួកគេអាចរស់នៅជាមួយដៃគូស្នេហាបានលុះត្រាតែឆ្លងកាត់ការក្រាបផ្ទឹមរៀបការដល់កន្ទេលតាមទំនៀមទម្លាប់ប្រពៃណីជាមុនសិន»។

និយាយដោយទឹកមុខម៉ឺងម៉ាត់ យុវជនវ័យក្មេងរូបនេះបានបន្ថែមទៀតថា ៖ «នេះជាទង្វើភ្លើតភ្លើនមួយពេលតាមរយៈការចម្លងយកវប្បធម៌ពីខាងក្រៅ តែលទ្ធផលយុវតីដែលប្រព្រឹត្តិបែបនេះអាចធ្វើឲ្យបាត់បង់កិត្តិយសខ្លួនឯងផ្ទាល់ និងក្រុមគ្រួសារ និងតម្លៃសង្គមខ្មែរ»។

ជាការពិតណាស់ការរស់នៅជាមួយគ្នាមុនពេលរៀបការពិតជាមិនត្រូវបានគេឱ្យតម្លៃឬគាំទ្រឡើយនៅក្នុងសង្គមខ្មែរពិសេសគឺភាគីជាស្រីតែម្តង ដោយហេតុថា នោះជាការបន្ទាបបន្ថោកតម្លៃគ្រួសារ ក៏ដូចជាប្រពៃណីខ្មែរទាំងមូល។ តែទោះបីជាមានមតិបដិសេធដាច់អហង្ការចំពោះទង្វើបែបនេះក្តី ក៏នៅមានយុវជនមួយចំនួនយល់ថាវាមិនមែនជាការខុសទាស់អ្វីនោះទេ។

ជាក់ស្តែង កញ្ញា ប៉ែន វិជ្ជនា ជានិស្សិតផ្នែកគីមីវិទ្យានៅសកលវិទ្យាភូមិន្ទភ្នំពេញវិញបានឱ្យដឹងថា៖ «វាត្រឹមត្រូវហើយដែលយើងជាយុវតីគួរតែគិតដល់បញ្ហានេះបើគិតដល់ទំនៀមទម្លាប់វប្បធម៌របស់ជាតិខ្លួន ប៉ុន្តែសម័យឥឡូវគេមិនសូវគិតច្រើនពេកនោះទេចំពោះរឿងហ្នឹង»។

កញ្ញា បន្តថា វាមិនមែនជារឿងធំដុំទេដែលគេឈានដល់ការរួមភេទមុនរៀបការ ពីព្រោះថារឿងដែលសំខាន់នោះគឺមនុស្សពីរនាក់ស្រលាញ់គ្នា ហើយគ្រាន់តែយុវតីខ្លួនឯងហ្នឹងចេះប្រុងប្រយ័ត្នកុំឲ្យថ្លោះធ្លោយរហូតដល់មានផ្ទៃពោះ»។

ចំណែក ស្រីល័ក្ខ និស្សិតឆ្នាំទី៤នៅសកលវិទ្យាល័យមួយនារាជធានីភ្នំពេញ ក៏មានទស្សនមិនខុសពីវិជ្ជនាប៉ុន្មានដែរ។ ស្រីល័ក្ខ បានបង្ហើបឲ្យដឹងថា កញ្ញាមានទំនាក់ទំនងស្នេហារយៈពេល២ឆ្នាំកន្លះ ប៉ុន្តែមិនបានរស់នៅផ្ទះជាមួយគ្នាទេ។ ប៉ុន្តែនាងព្យាយាមលាក់រឿងនេះមិនឲ្យក្រុមគ្រួសារដឹងឡើយ។

យុវនិស្សិតរូបនេះបានប្រាប់ទៀតថា ម្តាយរបស់នាងក៏បានស្គាល់មិត្តប្រុសរបស់នាង ប៉ុន្តែគាត់មិនបានដឹងពីទំនាក់ទំនងផ្លូវភេទរបស់នាង និងមិត្តប្រុស។ ស្រីល័ក្ខ ប្រាប់ថាម្តាយរបស់នាងមិនហាមប្រាមនាងមិនឱ្យមានសង្សារនោះទេ តែសំខាន់មិនឱ្យប្រព្រឹត្តិខុសប្រពៃណី ដូច្នេះហើយទើបនាងលាក់រឿងរួមភេទជាមួយដៃគូមិនឱ្យម្តាយដឹង។

ញញឹមបណ្តើរ ស្រីល័ក្ខឆ្លៀតនិយាយបណ្តើរ៖ «បើទោះបីជាពួកគេបានរួមរស់ជាមួយគ្នាមុនរៀបការក្តី ខ្ញុំមិនបានគិតថាខ្លួនខ្ញុំជាស្រីចិត្តងាយឡើយ។ សម្រាប់កញ្ញាស្រីល័ក្ខគិតថាខ្លួនជានារីល្អម្នាក់ ហើយជានារីដែលដៃគូចង់បានជាគូអនាគត។ ពួកយើងក៏មានគម្រោងរៀបចំអនាគតជាមួយគ្នាពេលណារៀនចប់ និងមានការងាររៀងៗខ្លួន»។

ពីជំនាន់មុន ការរៀបអាពាហ៍ពិពាហ៍ភាគច្រើនជាការរៀបចំឡើងដោយឪពុកម្តាយ ហើយមានពេលខ្លះភាគីកូនកំលោះកូនក្រមុំមិនទាំងធ្លាប់ឃើញមុខគ្នាម្តងផងមុនថ្ងៃរៀបការ។ ដោយឡែក ពេលបច្ចុប្បន្ននេះភាគច្រើនគូស្នេហ៍ស្វែងយល់ចិត្តគ្នាជាមុនសិនទើបគេធ្វើការសម្រេចចិត្តរៀបការជាក្រោយ។

ទាក់ទងនឹងបញ្ហានេះ គ្រូបង្រៀនផ្នែកអក្សរសាស្ត្រខ្មែរនៅវិទ្យាល័យបាក់ទូក លោក លឹម សុខចិន្តា បានផ្តល់ជាយោបល់ថា នេះជាការវិវឌ្ឍរបស់សង្គម យុវជនហ៊ានប្រឡូកក្នុងរឿងស្នេហា។

លោកបន្តថា ៖ «ការរីកចំរើននូវប្រព័ន្ធអ៊ីនធឺណិតគ្រប់ទីកន្លែងជាកត្តា ទាក់ទាញនាំឲ្យគេចង់សាកល្បងការរួមភេទ ប៉ុន្តែចំពោះយុវជនដែលស្រលាញ់ការរៀនសូត្រគេផ្តោតច្រើនទៅលើការសិក្សាទោះបីគេមានស្នេហាប្រុសស្រីក្តី»៕

# យុវជនខ្មែរជំនាន់ក្រោយមួយចំនួនពិតជាមិនចង់ធ្វើស្រែចំការ

*អត្ថបទ៖ អរិយក្សត្រ*

ទោះបីជា វិស័យកសិកម្ម ជាពិសេសស្រែចំការបន្ត មានស្ថានភាពវិជ្ជមាន ប៉ុន្តែយុវជនខ្មែរមួយចំនួន មិនចង់ធ្វើការងារនេះដូចជាសមាជិកគ្រួសាររបស់ពួកគេឡើយ។

លោក សេត សាត កសិករមួយរូបនៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ បានឲ្យដឹងថា ក្មេងៗឥឡូវមិនចង់បន្តធ្វើស្រែចំការទេ ឲ្យតែធំឡើងខ្លះមិនទាន់រៀនចប់ក៏រត់ទៅរកការងារធ្វើនៅថៃ ឬនៅទីក្រុងអស់ហើយ។

លោកបានបញ្ជាក់ថា ៖ «ក្មេងឥឡូវជើងវែងណាស់ ឱ្យតែធំ គេរត់ចោលស្រែចំការអស់ហើយ»។ លោកបានបន្តថា នៅពេលនេះអ្នកដែលមានបណ្តាញគេចេញទៅរកការងារធ្វើនៅថៃ ហើយ អ្នកខ្លះទៀតចេញទៅសៀមរាប ហើយមានខ្លះមកទីក្រុងភ្នំពេញជាដើម។

មិនមែនតែយុវជន និងយុវនារីនៅខេត្តឧត្តរមានជ័យមួយទេ សូម្បីតែនៅត្រឹមស្រុកស្ទោង ខេត្តកំពង់ធំ ក៏ត្រូវបានចាស់ៗនៅក្នុងភូមិអះអាងអំពីស្ថានភាពមិនខុសគ្នាពីខាងខេត្តឧត្តរមានជ័យដែរ។

អ្នកស្រី ជុំ សាវាត កសិករនៅម្តុំផ្សារស្ទោង បានថ្លែងប្រាប់ថា សម័យនេះឱ្យក្មេងៗមកជួយធ្វើស្រែគឺដឹងតែចប់ហើយ។ អ្នកស្រីបានអះអាងថា ក្មេងៗសម័យឥឡូវនេះគេមិនចេះធ្វើស្រែអីទេ គេដឹងតែហូបប៉ុណ្ណោះ ហើយឱ្យតែធំ បានត្រឹមតែ ១៤ ទៅ១៥ ឆ្នាំ គេបបួលគ្នាមកទីក្រុងរកការងារធ្វើ នៅតាមផ្ទះ តាមហាង តាមផ្សារ ហើយ។

អ្នកស្រី សាវាត បានបញ្ជាក់ថា ៖ «ដូចកូនស្រីខ្ញុំ គិតថាចង់ឱ្យគេរៀនចប់កុំឱ្យល្វិតល្វង់ធ្វើស្រែក្រីក្រដូចខ្ញុំ ប៉ុន្តែមានឯណា បានត្រឹមតែថ្នាក់ទី៦ គេថាឈប់រៀន ហើយទៅធ្វើការនៅទីក្រុងជាមួយមីងគេបាត់ទៅ»។



ចំណែកកសិករនៅស្រុកក្រឡាញ់ខេត្តសៀមរាប លោក ទុំ ប៉យ ក៏បានលើកឡើងដែរថា ក្មេងឥឡូវតាមគ្នា ហើយពួកគេមិនចង់ប្រឡាក់ប្រឡូកនឹងរឿងស្រែចំការទេ ដូចនេះហើយ មានតែចាស់ៗនៅបន្តធ្វើការងារតាមស្រែចំការទៀត។

លោកថា ៖ «ក្មេងៗដែលឃើញនៅក្នុងភូមិសព្វថ្ងៃគឺអ្នកដែលគ្រាន់ៗបើ ហើយនៅរៀនទេ បើក្រីក្រដឹងតែចេញទៅរកការងារធ្វើអស់ហើយ។ ធ្វើស្រែចំការ ពិតជាយ៉ាប់ ព្រោះមួយឆ្នាំកាក់កប មួយឆ្នាំឡុងចុង ចឹងហើយ បានជាក្មេងៗវាមិនចង់ធ្វើ»។

នេះគឺជាស្ថានភាពពិតនៅតាមវាលស្រែដែលកំពុងតែបង្កបង្កើនផល ផលិតស្រូវ និងអង្ករសម្រាប់នាំចេញរបស់កម្ពុជា ដែលមកដល់ពេលនេះស្ថិតិខាងសមាគមស្រូវអង្ករកម្ពុជាបានអះអាងថា ការនាំចេញកំពុងតែមាននិន្នាការប្រសើរ។

ស្ថិតិបានអះអាងថា នៅឆមាសទីមួយនៃឆ្នាំ២០២៣ នេះ ការនាំចេញអង្ករសម្រេចបាន ៣២៩, ៦៣៣ តោននៅក្នុងទឹកប្រាក់ប្រមាណជា ២២៩ លានដុល្លារ ពោលគឺសម្រេចបាន ៥០ភាគរយនៃផែនការ ៧០ម៉ឺនតោន ខណៈដែលការនាំចេញស្រូវ គឺមានរហូតដល់ទៅ ២,២២ លានតោន នៅក្នុងតម្លៃរហូតដល់ទៅជិត ៥៧៩លានដុល្លារ ។

ការនាំចេញអង្ករទៅដល់គោលដៅ៥២ ប្រទេស ដោយក្រុមហ៊ុននាំចេញ ៥០ ក្រុមហ៊ុន តែចិន គឺមានបរិមាណច្រើនជាងគេ ដោយមានរហូតដល់ទៅ ១៣៨, ៣៦៤ តោន បន្ទាប់មកទៅអឺរ៉ុប ប្រមាណជា ១២២, ១១៧ តោន បន្ទាប់មកមានអាស៊ាន ជាដើម៕

# វិទ្យាស្ថានបារាំងចុងបូព៌ា ប្រគល់វត្ថុបុរាណជូនអាជ្ញាធរជាតិអប្សរា

*អត្ថបទ៖ អមរិន្ទ ដានុត*

សាលាបារាំងចុងបូព៌ា (EFEO) ដែលជាដៃគូកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរជាតិអប្សរា ដើម្បីបំពេញការងារអភិរក្ស និងស្រាវជ្រាវនៅរមណីយដ្ឋានអង្គរ បានប្រគល់វត្ថុបុរាណចំនួន៣១កេស បដិមាព្រះពុទ្ធចំនួន០១ និងបំណែកសន្លឹកសីមាចំនួន០១ ជូនអាជ្ញាធរជាតិអប្សរា។

យោងតាមអាជ្ញាធរជាតិអប្សរា នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៣ បានលើកឡើងថា សាលាបារាំងចុងបូព៌ា (EFEO) ប្រគល់ជូននេះ ដើម្បីរក្សាទុកបន្ទាប់ពីបានសិក្សាស្រាវជ្រាវ និងរៀបចំបញ្ជីសារពើភណ្ឌរួចរាល់។



លោក ទិន ទីណា ជាអនុប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងផ្សព្វផ្សាយ បានឱ្យដឹងថា វត្ថុបុរាណទាំងអស់ដែលវិទ្យាស្ថានសាលាបារាំងចុងបូព៌ា (EFEO) ប្រគល់មកអាជ្ញាធរជាតិអប្សរា បានរកឃើញដោយការធ្វើកំណាយនៅតាមការដ្ឋានស្រាវជ្រាវមួយចំនួននៅក្នុងរមណីយដ្ឋានអង្គរ ដូចជា គោកតាសៀម បឹងដូនប៉ា ប្រាសាទអ៊ុងម៉ុង ប្រាសាទបាគួន និងប្រាសាទព្រៃមន្ទីរ។






លោកបានបញ្ជាក់ទៀតថា វត្ថុទាំងនេះរួមមាន ទី១ កុលាលភាជន៍មកពីប្រាសាទបាគួនចំនួន២៧កេស ដែលក្នុងនោះ មានប្រភេទកុលាលភាជន៍រឹង កុលាលភាជន៍ផុយជារបស់ខ្មែរ និងកុលាលភាជន៍ចិន សៀម យួនជាដើម។ ទី២ ថ្មភក់ចំនួន២កេស ដែលមកពីគោកតាសៀម។ ទី៣ បំណែកថ្មភក់មានក្បាច់លម្អខ្លះៗចំនួន២កេស មកពីបឹងដូនប៉ា និងគោកតាសៀមព្រមទាំងប្រាសាទអ៊ុងម៉ុង។ ទី៤ បដិមាព្រះពុទ្ធចំនួន០១ មកពីប្រាសាទអ៊ុងម៉ុង និងបំណែកសន្លឹកសីមាចំនួន០១ មកពីប្រាសាទព្រៃមន្ទីរ។

លោក ទិន ទីណា បន្តឱ្យដឹងទៀតថា ៖ «ក្រោយពីទទួលបានវត្ថុទាំងអស់នេះ ក្រុមអ្នកជំនាញរបស់អាជ្ញាធរជាតិអប្សរានឹងរៀបចំទុកដាក់អភិរក្សតាមលក្ខណៈបច្ចេកទេស ហើយនៅថ្ងៃខាងនេះ អាជ្ញាធរជាតិនឹងរៀបចំពិព័រណ៌មិនអចិន្ត្រៃយ៍នៅក្នុងសារមន្ទីរព្រះនរោត្តមសីហនុ-អង្គរ ដើម្បីតាំងបង្ហាញឱ្យសាធារណជនជាតិ និងអន្តរជាតិបានទស្សនា សិក្សាស្វែងយល់ពីវត្ថុសិល្បៈខ្មែរ»។

សូមរំឭកដែរថា នេះជាលើកទី៣ហើយ ដែលវិទ្យាស្ថានសាលាបារាំងចុងបូព៌ា (EFEO) បានប្រគល់បុរាណវត្ថុដែលបានមកពីកំណាយនៅតាមការដ្ឋានស្រាវជ្រាវ និងការដ្ឋានជួសជុលប្រាសាទមួយចំនួននៅក្នុងរមណីយដ្ឋានអង្គរមកដល់អាជ្ញាធរជាតិអប្សរា៕

# ម្ទេស អាចប្រមូលផលបាន ចាប់ពីដាំដុះរយៈពេល ៦៥ ទៅ៨០ថ្ងៃ អាស្រ័យលើពូជ



*ប្រភព៖ ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ*

ម្ទេសជាប្រភេទបន្លែដែលពេញនិយមប្រើប្រាស់ និងបានដាំដុះពាសពេញពិភពលោក ដែលមានលក្ខណៈពិសេសម្យ៉ាងគឺមានជាតិហឹរ ហើយកម្រិតហឹររបស់វាទៅតាមប្រភេទរបស់ម្ទេសនីមួយ។

ដំណាំម្ទេសមានច្រើនប្រភេទ ដែលនៅប្រទេសកម្ពុជាគេនិយមដាំប្រភេទ ម្ទេសដៃនាង ម្ទេសអាចម៍សត្វ ម្ទេសផ្លោក ម្ទេសហាវ៉ៃ ដោយឡែកម្ទេសផ្សេងៗទៀតដែលឃើញលក់នៅតាមទីផ្សារជាប្រភេទម្ទេសនាំចូលមកដាំដុះដែលពុំទាន់មានការសិក្សាពីបច្ចេកទេសដាំដុះសមស្របនៅឡើយទេ។

ម្ទេសជាបន្លែដែលសម្បូរវីតាមីនដូចជា A B C E និងសារធាតុរ៉ែ ដែលមានមុខងារជួយដល់សារពាង្គកាយមនុស្ស ដូចជាជួយបន្សាបជាតិពុល បំបាត់ការឈឺចាប់ ជាថ្នាំអង់ទីប៊ីយ៉ូទិចធម្មជាតិ ជួយភ្ញោចខួរក្បាលក្នុងការបញ្ចេញអ័រម៉ូន endorphins ជួយកាត់បន្ថយមហារីកពោះវៀនធំ និងជួយបញ្ចុះជាតិកូឡេស្តេរ៉ូលក្នុងឈាមដែលអាចកាត់បន្ថយជំងឺគាំងបេះដូង ប៉ុន្តែមិនត្រូវពិសារលើសកម្រិតនោះទេ។

ម្ទេសត្រូវបានដាំដុះស្ទើគ្រប់ទីកន្លែង ដោយសារតម្រូវការប្រើប្រាស់វាជាចាំបាច់ក្នុងការចម្អិនមុខម្ហូប ឬតាមចំណង់ចំណូលចិត្តអ្នកប្រើប្រាស់វា។

នៅប្រទេសយើងម្ទេសហឹរមិនមែនជាបន្លែចម្បងក្នុងមុខម្ហូបទេ គេច្រើនប្រើវាសម្រាប់បន្ថែមសម្រស់ឱ្យម្ហូបអាហារ ឬបន្ថែមរស់ជាតិហឹរតាមការចូលចិត្ត ដោយឡែកម្ទេសដែលមានជាតិហឹរតិចដូចជាម្ទេសហាវ៉ៃ និងម្ទេសផ្លោក ត្រូវបានចម្អិនជាអាហារគោលដូចជាឆា ស្ល ឬញាំជាមួយបន្លែផ្សេង។

ក្រៅពីបរិភោគស្រស់ និងចម្អិន គេក៏អាចកែច្នៃជាម្ទេសជ្រក់ និងម្ទេសក្រៀមផងដែរ សម្រាប់ម្ទេសផ្លោកគេអាចកែច្នៃជាម្ទេសឆ្អេរសម្រាប់ប្រើប្រាស់ក្នុងសម្លរការី និងម្ហូបផ្សេងទៀត ចំណែកម្ទេសហឹរក្រៀម គេច្រើនកិនទុកបន្ថែមរស់ជាតិហឹរឱ្យអាហារ។

ម្ទេសមិនរើសដីដាំដុះទេ ប៉ុន្តែដីដែលល្អសម្រាប់ម្ទេសគឺជាដីមានជីជាតិល្អ ក្បែរប្រភពទឹក ឬជាដីល្បាប់ល្បាយខ្សាច់ ធូរ សម្បូរទៅដោយជាតិមោគ និងសារធាតុចិញ្ចឹមខ្ពស់ វាត្រូវការទឹកជាមធ្យមក្នុងកម្រិតសំណើមដីពី ៦៥ ទៅ៧០ភាគរយ។

ដំណាំម្ទេសមិនងាយស្រួលក្នុងការដាំដុះប៉ុន្មានទេ វាមានជំងឺច្រើនដូច្នេះកសិករត្រូវយល់ដឹង និងអនុវត្តបច្ចេកទេសសមដូចជាការជ្រើសពូជ រៀបចំដីដាក់ជី បញ្ចេញបញ្ចូលទឹក និងថែទាំ ទើបទទួលបានទិន្នផលល្អ។

ការដាំម្ទេសនៅរដូវក្តៅមានបញ្ហាប្រឈមច្រើនដូចជា សត្វល្អិត បាក់តេរី វីរុស និងពពួកផ្សិត ហើយរដូវកាលសមស្របសម្រាប់ដំណាំម្ទេស គឺរដូវរំហើយចាប់ពីខែតុលា និងវិច្ឆិកា ប្រមូលផលនៅខែកុម្ភៈ និងដាំនៅរដូវប្រាំងចាប់ពីខែឧសភា ប្រមូលផលនៅខែសីហា។

ម្ទេសជាដំណាំមិនប្រកាន់រដូវអាចដាំដុះបានពេញមួយឆ្នាំ អាចប្រមូលផលបានចាប់ពីដាំដុះរយៈពេល ៦៥ ទៅ៨០ថ្ងៃ អាស្រ័យតាមពូជដែលបានជ្រើសរើស ហើយអាចប្រមូលបានច្រើនដងបន្តបន្ទាប់គ្នា។

បើតាមការចុះផ្សាយតម្លៃបោះដុំផលិតផលកសិកម្ម ប្រចាំថ្ងៃ នៅលើគេហទំព័រក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឱ្យដឹងថា គិតចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២៣នេះ ម្ទេសស្រស់មានតម្លៃប្រែប្រួលចន្លោះពី ៤០០០រៀល ទៅ៩០០០រៀល ក្នុងមួយគីឡូក្រាម។

បើមើលពីនិន្នាការតម្លៃរយៈ៥ឆ្នាំ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៣ នេះតម្លៃម្ទេសអាចហក់ខ្ពស់បំផុតដល់ទៅ ២០ ០០០រៀលក្នុងមួយគីឡូក្រាមក្នុងខែមិថុនា និងខែមករា និងធ្លាក់ថ្លៃទាបបំផុតត្រឹមតម្លៃ ៦០០រៀលក្នុងមួយគីឡូក្រាមនៅក្នុងខែតុលា លើសពីនេះតម្លៃម្ទេសមានការប្រែប្រួលគម្លាតតម្លៃខ្លាំងនៅក្នុងរដូវប្រាំង និងប្រែប្រួលតិចតួចនៅរដូវវស្សា៕

# ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ផ្ដល់កម្ចី១០០លានដុល្លារ





*អត្ថបទ៖ អមរិទ្ធ ដានុត*

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានអនុម័តប្រាក់កម្ចីចំនួន ១០០ លានដុល្លា ដើម្បីជួយលើកកម្ពស់សមត្ថភាពកម្លាំងពលកម្មរបស់កម្ពុជាដោយដោះស្រាយគម្លាត និងកង្វះខាតជំនាញ។

ការងារនេះនឹងធ្វើឡើងតាមរយៈកំណែទម្រង់ និងការ វិនិយោគលើវិស័យអប់រំ និងបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ (TVET) រួមជាមួយនឹងការចូលរួមពីវិស័យឯកជន។ នេះបើយោងតាមសេចក្ដីប្រកាសព័ត៌មានរបស់ADB។

ADB បានលើកឡើងថា កម្មវិធីរងទីមួយ នៃកម្មវិធីអភិវឌ្ឍន៍វិស័យជំនាញសម្រាប់សេដ្ឋកិច្ចនាពេលអនាគត នឹងជួយប្រែក្លាយកម្ពុជាទៅជាសេដ្ឋកិច្ចឧស្សាហកម្មដែលផ្អែកលើចំណេះដឹង និងជំរុញដោយបច្ចេកវិជ្ជា តាមរយៈការពង្រឹងធនធានមនុស្ស ដោយផ្ដោតលើការលើកកម្ពស់បរិយាកាសអភិវឌ្ឍន៍ជំនាញរបស់ប្រទេស ផ្ដល់ការបណ្ដុះបណ្ដាលប្រកបដោយបរិយាបន្នដែលនាំមុខដោយឧស្សាហកម្ម និងកៀរគរមូលនិធិបន្ថែមសម្រាប់ការអភិវឌ្ឍជំនាញដែលផ្ដោតលើតម្រូវការ។

លោកស្រី Jyotsana Varma នាយិកាធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំប្រទេសកម្ពុជាមានប្រសាសន៍ថា៖ «ការកែទម្រង់កម្លាំងពលកម្ម និងការធ្វើទំនើបកម្មសេដ្ឋកិច្ចរបស់កម្ពុជា ទាមទារឱ្យមាន កំណែទម្រង់ជាបន្តនៃប្រព័ន្ធ TVET តាមរយៈយុទ្ធសាស្ត្រស៊ីជម្រៅ និងការវិនិយោគជាបន្តបន្ទាប់ ឱ្យទាន់ ពេលវេលា»។

លោកស្រីបន្តថា កំណែទម្រង់រចនាសម្ព័ន្ធ និងស្ថាប័នTVETទាំងនេះ មានសារសំខាន់សម្រាប់ការរៀបចំកម្មវិធីបណ្ដុះបណ្ដាលដែលឆ្លើយតបនឹងតម្រូវការទីផ្សារ ធ្វើឱ្យប្រសើរឡើងនូវទីតាំងនិងឧបករណ៍បណ្ដុះ បណ្ដាល និងពង្រីកមូលនិធិអភិវឌ្ឍន៍ជំនាញ (SDF)។

យោងតាមសេចក្ដីប្រកាសដដែល មូលនិធិអភិវឌ្ឍន៍ជំនាញ ត្រូវបានសាកល្បងដោយរាជរដ្ឋាភិបាល ក្រោមគម្រោងជំនាញសម្រាប់ភាពប្រកួតឈ្នះ ផ្ដល់ហិរញ្ញប្បទានដោយ ADB ដែលត្រូវបានអនុម័តក្នុងឆ្នាំ ២០១៩ ដើម្បីបង្កើនជំនាញ និងសមត្ថភាពប្រកួតប្រជែងនៃកម្លាំងពលកម្មដែលកំពុងកើនឡើងរបស់កម្ពុជា។

ប្រភពដដែលថា ការដាក់សាកល្បង SDF នេះ បាននឹងកំពុងឆ្លើយតបទៅនឹងតម្រូវការបណ្ដុះបណ្ដាលជំនាញសម្រាប់វិស័យឧស្សាហកម្ម តាមរយៈ ភាពជាដៃគូសហហិរញ្ញប្បទានជាមួយស្ថាប័នរាជរដ្ឋាភិបាល ផ្នែកឧស្សាហកម្ម ភ្នាក់ងារផ្ដល់ការបណ្ដុះ បណ្ដាល និងដៃគូអភិវឌ្ឍន៍នានា។

បញ្ហាប្រឈមសំខាន់ៗចំនួនបី រួមចំណែកជាឧបសគ្គទូទៅ ដែលកំពុងជាបញ្ហាប្រឈមសម្រាប់ ប្រព័ន្ធ TVET កម្ពុជា គឺកង្វះកម្មវិធីអភិវឌ្ឍន៍ជំនាញជាក់លាក់ និងស៊ីជម្រៅសម្រាប់បដិវត្តន៍ឧស្សាហកម្មទីបួន, ភាពមានកម្រិតនៃតួនាទីរបស់វិស័យឯកជនក្នុងការអភិវឌ្ឍជំនាញ និងនៃចក្ខុវិស័យអន្តរកម្មរបស់ឧស្សាហកម្មនានា និងការផ្ដល់ហិរញ្ញប្បទាន និងភាពជាដៃគូមិនទាន់បានពេញលេញ ក្នុងការអភិវឌ្ឍជំនាញ។

ធនាគារអភិវឌ្ឍន៍អាស៊ី បន្តថា មានអ្នកធ្វើការប្រមាណ ៩លាននាក់ក្នុងទីផ្សារការងារនៅកម្ពុជាដែលក្នុងនោះមានស្ត្រី ៤៩% នៃកម្លាំងពលកម្មទាំងនោះ។ គិតត្រឹមឆ្នាំ ២០២១ ប្រជាពលរដ្ឋកម្ពុជា៥៤%មានអាយុក្រោម ៣០ ឆ្នាំដែល នេះបង្ហាញពីឱកាសពិសេសមួយសម្រាប់ប្រទេសក្នុងការបង្កើនការវិនិយោគលើការអភិវឌ្ឍធនធានមនុស្សដើម្បីបង្កើនជំនាញសម្រាប់និយោជិតថ្មីចូលទៅក្នុងទីផ្សារការងារ និងលើកកម្ពស់ជំនាញរបស់និយោជិត ដែលកំពុងបំពេញការងារទៅតាមតម្រូវការឧស្សាហកម្មផងដែរ៕

# ស្ថានភាពយុវជននៅកម្ពុជា មិនអាក្រក់ពេកនោះទេ



*អត្ថបទ៖ អរិយបុត្រ*

តារាងសន្ទស្សន៍អភិវឌ្ឍន៍យុវជនអាស៊ានឆ្នាំ ២០២២ដែលទើបតែចេញផ្សាយនាពេលថ្មីៗកន្លងទៅនេះដោយលេខាធិការដ្ឋានអាស៊ានបានបង្ហាញថា ស្ថានភាពយុវជនកម្ពុជាមិនអាក្រក់ពេកនោះឡើយប្រសិនបើប្រៀបធៀបនឹងយុវជននានានៅក្នុងតំបន់។

របាយការណ៍ដែលបានចេញផ្សាយកាលពីពាក់កណ្ដាលខែ កក្កដា បានឲ្យដឹងថា នៅក្នុងចំណោម១០ប្រទេស យុវជនកម្ពុជា បានទទួលពិន្ទុ ០,៥៦៨ ដែលប្រសើរជាងយុវជននៅក្នុងប្រទេស មីយ៉ាន់ម៉ា ដែលមានពិន្ទុសរុបត្រឹមតែ ០,៤៦៦, ឡាវ ទទួលបានពិន្ទុត្រឹមតែ០,៤៧៦, ហ្វីលីពិន មានពិន្ទុត្រឹមតែ ០,៥២២ ។

ប្រភពដដែលបានបន្តទៀតថា ក្រៅពីនោះកម្ពុជាមានស្ថានភាពប្រហាក់ប្រហែលនឹងឥណ្ឌូនេស៊ី ដែលមាន ០,៥៧៨ និង ថៃ ដែលទទួលបានពិន្ទុប្រមាណជា ០,៥៧៤ ពិន្ទុ។

លេខាធិការដ្ឋានអាស៊ានបានអះអាងថា របាយការណ៍នេះគឺជាការស្ទាបស្ទង់អំពីស្ថានភាពផ្សេងៗដែលទាក់ទងនឹងយុវជន ដោយសារតែយុវជនគឺជាគន្លឹះក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ទាំងបច្ចុប្បន្ន និងទៅអនាគត។

ប្រភពដដែលបានបន្តថា ក្នុងនាមជាអ្នកដឹកនាំដែលជិតមកដល់ អ្នកបង្កើតការផ្លាស់ប្ដូរ អ្នកបង្កើតថ្មី និងអ្នកមានឥទ្ធិពល យុវជនរបស់អាស៊ានចាំបាច់ត្រូវផ្ដល់ឱកាសដ៏មានអត្ថន័យដើម្បីមានឥទ្ធិពលលើគោលនយោបាយដែលមានឥទ្ធិពលផ្ទាល់លើជីវិតរបស់ពួកគេ។

អាស្រ័យហេតុនេះ រដ្ឋសមាជិកអាស៊ាន (AMS) បានបន្តកិច្ចខិតខំប្រឹងប្រែងដោយចេតនាឆ្ពោះទៅរកការបង្កើត និងអនុវត្តគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍យុវជនផ្អែកលើភស្តុតាង ដើម្បីដឹងពីសក្ដានុពលនៃផ្នែកនៃចំនួនប្រជាជនអាស៊ាននេះ។

របាយការណ៍នេះ ត្រូវបានចេញផ្សាយដើម្បីជួយនៅក្នុងការកំណត់ គោលនយោបាយទាក់ទងនឹងយុវជន និងយុទ្ធសាស្ត្រអភិវឌ្ឍន៍យុវជន ដោយផ្ដល់នូវហេដ្ឋារចនាសម្ព័ន្ធចាំបាច់ក្នុងការពូនជ្រុំយុវជនដែលមានបំណងចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសនីមួយៗ និងអាស៊ានទាំងមូល។

ប្រភពដដែលបានបន្តថា សន្ទស្សន៍ដែលគេបានចងក្រងនេះ បានបញ្ចូលការបង្កើត និងប្រើប្រាស់សន្ទស្សន៍អភិវឌ្ឍន៍យុវជនអាស៊ាន ដើម្បីធ្វើជារង្វាស់នៃសមិទ្ធផលនៅក្នុងវិមាត្រសំខាន់ៗនៃការអភិវឌ្ឍន៍យុវជននៅទូទាំងតំបន់ ដោយផ្ដោតនៅលើការអប់រំ និងជំនាញ សុខភាព និងសុខុមាលភាព ការងារ និងឱកាស ការចូលរួម និងសមធម៌ ព្រមទាំងការដាក់បញ្ចូល សន្តិសុខ និងសុវត្ថិភាព ព្រមទាំងតម្លៃ និងអត្តសញ្ញាណអាស៊ានផងដែរ។

លោក កៅ គឹមហួន អគ្គលេខាធិការអាស៊ាន បានលើកឡើថា យុវជននៅក្នុងតំបន់មានចំនួនសរុប មួយភាគបីនៃចំនួនប្រជាជនអាស៊ីអាគ្នេយ៍។ យុវជន គឺជាកម្លាំងចលករដ៏សំខាន់មួយនៃការអភិវឌ្ឍនិងការច្នៃប្រឌិតរបស់តំបន់ និងដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចខិតខំប្រឹងប្រែង កសាងសហគមន៍របស់អាស៊ាន។

លោក កៅ គឹមហួន ក៏បានជំរុញឲ្យរដ្ឋជាសមាជិកអាស៊ានបានប្ដេជ្ញាចិត្តក្នុងការបំពាក់ឱ្យពួកគេនូវចំណេះដឹង និងជំនាញចាំបាច់ដើម្បីរីកចម្រើនក្នុងពិភពលោកដែលផ្លាស់ប្ដូរយ៉ាងឆាប់រហ័ស៕



# សម្ដេចតេជោ ហ៊ុន សែន ប្រកាសលាលែងតំណែងនាយករដ្ឋមន្ត្រី

*អត្ថបទ៖ អមរិន្ទ ដានុត*

ក្រោយការបោះឆ្នោតរយៈពេល៣ថ្ងៃ ពោលគឺនៅថ្ងៃទី២៦ ខែកក្កដា សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចេញមកប្រកាសជាសាធារណៈដល់ប្រជាពលរដ្ឋនៅទូទាំងប្រទេសថា សម្ដេចនឹងមិនបន្តតំណែងជានាយករដ្ឋមន្ត្រីទៀតនោះទេ បើទោះបីជាលោកធ្លាប់បានប្រកាសថាជាបេក្ខជននាយករដ្ឋមន្ត្រីសម្រាប់នីតិកាលទី៧ក៏ដោយ។

សម្ដេចបានថ្លែងឡើងតាមរយៈការផ្សាយពិសេសនារសៀលថ្ងៃទី២៦ ខែកក្កដា បន្ទាប់ពីលោកបានចូលក្រាបថ្វាយបង្គំព្រះមហាក្សត្ររួច។

សម្ដេចតេជោ ហ៊ុន សែន បានបញ្ជាក់ថា ៖ «ដោយសារតែសភាពការណ៍គឺបានតម្រូវឱ្យត្រូវធ្វើការរៀបចំរាជរដ្ឋាភិបាលចាប់ពីដើមអាណត្តិនេះទៅ ដើម្បីជានានូវភាពរលូននៃដំណើរការរាជរដ្ឋាភិបាលដោយគ្មានអាក់ខាន។ បើខ្ញុំបន្តធ្វើជានាយករដ្ឋមន្ត្រីក្នុងរយៈពេល១ឬ២ឆ្នាំ រួចហើយទើបលាលែងចេញពីតំណែងសភាពការណ៍នឹងមានអស្ថេរភាពក្នុងមួយរយៈកាល»។

បើតាមការបង្ហើបឱ្យដឹងពីសម្ដេចតេជោ វាជាការចាំបាច់ណាស់ដែលត្រូវឱ្យគណៈរដ្ឋមន្ត្រីថ្មីមួយដែលភាគច្រើនសុទ្ធតែជាមនុស្សវ័យក្មេងទទួលបាននូវកិច្ចការដែលពួកគេត្រូវទទួលខុសត្រូវសម្រាប់ទៅថ្ងៃអនាគត។





នាយកប្រតិបត្តិអង្គការឃ្លាំមើលការបោះឆ្នោត ហៅកាត់ថា និកហ្វិក លោក សំ គន្ធាមី បានលើកឡើងថា ការប្រកាសមិនបន្តធ្វើជានាយករដ្ឋមន្ត្រី និងប្រកាសបេក្ខជននាយករដ្ឋមន្ត្រីថ្មី គឺលោក ហ៊ុន ម៉ាណែត នេះ គឺវាជានីតិវិធីរបស់គណបក្សប្រជាជនកម្ពុជាដែលត្រូវបានរៀបចំនាពេលកន្លងមក។

លោកបានថ្លែងថា ៖ «វាជាការល្អផងដែរ នៅពេលដែលកម្ពុជាមានយុវជន ធ្វើជានាយករដ្ឋមន្ត្រីដឹកនាំប្រទេស ហើយក៏ពលរដ្ឋក៏ដូចជាអង្គការសង្គមស៊ីវិល កំពុងរង់ចាំមើលផងដែរពីស្នាដៃរបស់នាយករដ្ឋមន្ត្រីថ្មី និងការដឹកនាំប្រទេស ឱ្យមានការប្រែប្រួលចំពោះការអនុវត្តសិទ្ធិមនុស្ស និងប្រទេសកម្ពុជាមានការអភិវឌ្ឍដូចម្ដេចខ្លះ»។

## ការលះបង់ដើម្បីជាតិ

សម្ដេចតេជោ ហ៊ុន សែន បានលើកឡើងថា សម្ដេច និងឥស្សរជនដទៃទៀតដែលមានអាយុ៧០ឆ្នាំឬលើស៧០ឆ្នាំរហូតដល់ជាង៨០ឆ្នាំ គប្បីត្រូវនៅពីខាងក្រោយខ្នង។

សម្ដេចបានឱ្យដឹងថា សម្ដេចត្រូវតែហ៊ានលះបង់អំណាចជាថ្មីម្ដងទៀត ខណៈដែលសម្ដេចធ្លាប់បានលះបង់ជាច្រើនកន្លងមកដើម្បីប្រទេសជាតិ និងការរស់រានមានជីវិតរបស់ប្រជាជនចេញពីរបបប្រល័យពូជសាសន៍ប៉ុលពត។

សម្ដេចមានប្រសាសន៍ថា ៖ «យើងត្រូវហ៊ានលះបង់ ខ្ញុំព្រះករុណាខ្ញុំត្រូវតែលះបង់សារជាថ្មីម្ដងទៀតនូវអំណាច ដែលមុននោះខ្ញុំបានយកក្បាលរបស់ខ្ញុំដើម្បីទៅដោះដូរជាមួយនឹងការរស់រានមានជីវិតរបស់ប្រជាជន គឺរំដោះប្រជាជនចេញពីរបបប្រល័យពូជសាសន៍ប៉ុលពត»។

សម្ដេចបន្តថា ៖ «បន្ទាប់មកខ្ញុំបានយកក្បាលរបស់ខ្ញុំទៅដោះដូរជាមួយនឹងសន្តិភាព ដោយបញ្ចប់នូវស ង្គ្រាម និងនាំមកនូវការបង្រួបបង្រួមជាតិ ឯកភាពជាតិ ឯកភាពទឹកដីជាលើកដំបូងនៅក្នុងរយៈពេលដ៏យូរនៃប្រទេសកម្ពុជា»។

សម្ដេចតេជិនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏បានយកជីវិតនយោបាយរបស់លោកទៅដោះដូរជាមួយនឹងកំណែទម្រង់នានាដែលធ្វើឱ្យព្រះរាជាណាចក្រកម្ពុជា ទទួលបានលទ្ធផលរហូតមកដល់ពេលនេះផងដែរ។

ការដែលសម្ដេចប្រញាប់ប្រញាល់លាឈប់ពីតំណែងជានាយករដ្ឋមន្ត្រីនេះ សម្ដេចបានបញ្ជាក់ថា វាគឺជាការរៀបចំទុកជាមុនសម្រាប់ការរក្សាស្ថេរភាពរយៈពេលវែង ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍ។

សម្ដេចតេជោ ហ៊ុន សែន ថ្លែងថា ៖ «ការចូលកាន់តំណែងរបស់ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត ជានាយករដ្ឋមន្ត្រីមិនបានរំលងនីតិវិធីទាំងឡាយនោះឡើយ»។

## សម្ដេច ហ៊ុន សែន កាន់កាប់តំណែងជានាយករដ្ឋមន្ត្រីអស់រយៈពេល ១៤ ០៩៩ថ្ងៃ

សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងឱ្យដឹងថា បើរាប់ចាប់ពីថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៨៥ រហូតដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ សម្ដេចធ្វើជានាយករដ្ឋមន្ត្រីអស់រយៈពេល ២ ០១៤ សប្ដាហ៍ ដែលស្មើនឹង ២៦៣ខែ ឬ៣៨ឆ្នាំ ៧ខែ ៨ថ្ងៃ ឬស្មើនឹង ១៤ ០៩៩ ថ្ងៃ។

សម្ដេចបានបន្តថា ៖ «គិតចាប់ពីថ្ងៃទី៨ ខែមករា ឆ្នាំ១៩៧៩ ដល់ថ្ងៃទី ២២ ខែសីហា ឆ្នាំ២០២៣ ខ្ញុំបានបំពេញការងារក្នុងរដ្ឋាភិបាល/រាជរដ្ឋាភិបាលចំនួន ២ ៣២៨ សប្ដាហ៍ ស្មើនឹង ១៦ ២៩៧ ថ្ងៃ ឬ៥៣៥ខែ ឬ៤៤ឆ្នាំ ៧ខែ និង៤ថ្ងៃ»។










តទៅទំព័រ-៨និង៩




« សម្រាប់អនាគតនយោបាយរបស់ខ្ញុំ ខ្ញុំព្រះករុណាខ្ញុំ នៅតែបន្តក្នុងមុខនាទីជាប្រធានគណបក្សកាន់អំណាច និងធ្វើជាសមាជិករដ្ឋសភា បន្ថែមលើនោះ គឺព្រះមហាក្សត្រ ព្រះអង្គទ្រង់នឹងព្រះរាជទានតែងតាំងខ្ញុំព្រះករុណាខ្ញុំ ជាប្រធានឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ នៅក្រោយពេលខ្ញុំព្រះករុណាខ្ញុំ ចាកចេញជាស្ថាពរពីគណៈរដ្ឋមន្ត្រី »

តពីទំព័រ-៧

បើគិតចាប់ពីថ្ងៃដែលសម្តេចយកជីវិតធ្វើជាដើមទន់ដើម្បីរំដោះជាតិ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ សម្តេច បានបំពេញការងារដើម្បីបុព្វហេតុជាតិ ៤៦ឆ្នាំ ២ខែ ២ថ្ងៃ ត្រូវជា ៥៥៤ខែ និងត្រូវជា ២៤០៩សប្តាហ៍ ឬ១៩ ៨៦៤ ថ្ងៃ។

## តើសម្តេចតេជោ ហ៊ុន សែន នឹងធ្វើអ្វីបន្ទាប់ពីបញ្ចប់តំណែងជានាយករដ្ឋមន្ត្រី?

បើតាមការបញ្ជាក់ឱ្យដឹងពីសម្តេចតេជោ ហ៊ុន សែន បន្ទាប់ពីចាកចេញពីឆាកនយោបាយដែលសម្តេចបានកាន់កាប់ជាច្រើនឆ្នាំមក រួមនឹងថ្នាក់ដឹកនាំកំពូលៗរបស់ប្រទេសកម្ពុជា មួយចំនួនទៀត ដូចជា លោកស្រី ម៉ែន សំអន, លោក ស ខេង, លោក ទៀ បាញ់, លោក ហេង សំរិន និងមន្ត្រីជាន់ខ្ពស់មួយចំនួនទៀតក៏នឹងត្រូវចាកចេញពីតួនាទីផងដែរ។

នៅក្នុងឱកាសចូលក្រាបថ្វាយបង្គំគាល់ព្រះមហាក្សត្រនៅព្រឹកថ្ងៃទី២៦ ខែកក្កដា ព្រះមហាក្សត្រនឹងត្រាស់បង្គាប់តែងតាំងសម្តេចតេជោជាប្រធានឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រ នៅពេលលាឈប់ពីរាជរដ្ឋាភិបាលផងដែរ។

សម្តេចតេជោ ហ៊ុន សែន មានប្រសាសន៍ថា ៖ «ក្រៅពីខ្ញុំព្រះករុណា សម្រេចឈប់ពីរាជរដ្ឋាភិបាល ក៏មានសម្តេចក្រឡាហោម ស ខេង, សម្តេចពិជ័យសេនា ទៀ បាញ់, សម្តេច ម៉ែន សំអន និងឧបនាយករដ្ឋមន្ត្រីមួយចំនួនទៀត ក៏នឹងចាកចេញពីតំណែងផងដែរ។ បើទោះបីជាខ្ញុំព្រះករុណាឈប់ ក្នុងការងាររាជរដ្ឋាភិបាល ប៉ុន្តែខ្ញុំនៅតែបន្តកាន់តំណែងជា ប្រធានគណបក្សប្រជាជនកម្ពុជាដដែល»។

សម្តេចតេជោ ហ៊ុន សែន បានបញ្ជាក់ដែរថា លោក ហេង សំរិន, លោក ស ខេង, លោក ទៀ បាញ់ និងលោកស្រី ម៉ែន សំអន ក៏នឹងត្រូវព្រះមហាក្សត្រ ត្រាស់បង្គាប់តែងតាំងជាឧត្តមទីប្រឹក្សាផ្ទាល់របស់ព្រះមហាក្សត្រផងដែរ។

សម្តេចបានថ្លែងថា ៖ «សម្រាប់អនាគតនយោបាយរបស់ខ្ញុំ ខ្ញុំព្រះករុណាខ្ញុំ នៅតែបន្តក្នុងមុខនាទីជាប្រធានគណបក្សកាន់អំណាច



និងធ្វើជាសមាជិករដ្ឋសភា បន្ថែមលើនោះ គឺព្រះមហាក្សត្រ ព្រះអង្គទ្រង់នឹងព្រះរាជទានតែងតាំង ខ្ញុំព្រះករុណាខ្ញុំ ជាប្រធានឧត្តមក្រុមប្រឹក្សាព្រះមហាក្សត្រនៅក្រោយពេលខ្ញុំព្រះករុណាខ្ញុំ ចាកចេញជាស្ថាពរពីគណៈរដ្ឋមន្ត្រី»។

បើតាមការបញ្ជាក់ពីប្រមុខរាជរដ្ឋាភិបាលអាណត្តិទី៦នេះ សម្តេចក៏នឹងទៅកាន់តំណែងជាប្រធានព្រឹទ្ធសភា ជំនួសលោក សាយ ឈុំ នៅក្នុងនីតិកាលថ្មីខាងមុខនេះដែរ បន្ទាប់ពីបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៤។

## លោក ហ៊ុន ម៉ាណែត នឹងក្លាយជានាយករដ្ឋមន្ត្រីថ្មីនៃប្រទេសកម្ពុជា ចាប់ពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣

ប្រធានគណបក្សប្រជាជនកម្ពុជា សម្តេចតេជោ ហ៊ុន សែន បានប្រកាសជាផ្លូវការនៅថ្ងៃទី២៦ ខែកក្កដាថា លោកបណ្ឌិត ហ៊ុន ម៉ាណែត នឹងត្រូវក្លាយជានាយករដ្ឋមន្ត្រីថ្មី នៅល្ងាចថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ បន្ទាប់ពីរដ្ឋសភាបើកកិច្ចប្រជុំលើកដំបូង។

សម្តេចបានបញ្ជាក់ថា ៖ «ខ្ញុំសូមបញ្ជាក់ប្រាប់ឱ្យច្បាស់ថា ហ៊ុន ម៉ាណែត នឹងចាប់ផ្តើមធ្វើនាយករដ្ឋមន្ត្រី នៅល្ងាចថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ខាងមុខ។ ហ៊ុន ម៉ាណែត នឹងក្លាយជានាយករដ្ឋមន្ត្រី ហើយអ្នកជ្រុលនិយមមួយចំនួន ពួកគេចង់ហៅនាយករដ្ឋមន្ត្រី ក៏ហៅទៅ មិនចង់ហៅ ក៏នៅក្រៅច្បាប់ទៅ ដោយសារតែប្រជាពលរដ្ឋជាង៨៤ភាគរយ បានបោះឆ្នោត ហើយក្នុងនោះមាន៨២ភាគរយ បានគាំទ្រ គឺគ្រប់គ្រាន់រួចទៅហើយ»។

## អ្នកដឹកនាំជំនាន់ក្រោយប្តេជ្ញាអភិវឌ្ឍន៍ប្រទេសទ្វេដង

លោក ហ៊ុន ម៉ានី អ្នកតំណាងរាស្ត្រពីគណបក្សប្រជាជនកម្ពុជា និងជាកូនប្រុសពៅលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងលើបណ្តាញសង្គមហ្វេសប៊ុករបស់លោកដោយបង្ហាញពីការលះបង់ដ៏ធំធេងរបស់សម្តេចតេជោ ហ៊ុន សែន ដែលជានាយករដ្ឋមន្ត្រី និងជាឪពុកបង្កើតរបស់លោកផងដែរ។

លោកបានឱ្យដឹងថា ៖ «មានរឿងរ៉ាវជាច្រើនដែលយើងត្រូវនិយាយ និងរៀនសូត្រពីការលះបង់ជាច្រើនរាប់មិនអស់របស់ពុក/សម្តេចតេជោនាយករដ្ឋមន្ត្រី សម្រាប់ជាតិមាតុភូមិ និងប្រជាជនតាំងពីយុវវ័យ រហូតដល់បច្ចុប្បន្នដែលមិនអាចមានពាក្យអ្វីនឹងថ្លែងអស់»។

លោកបានបន្តថា នេះជាការលះបង់ដ៏ធំធេងមួយទៀតរបស់លោក ក្នុងការមិនបន្តកាន់តំណែងជានាយករដ្ឋមន្ត្រី (បើទោះបីជាលោកនៅអាចបន្តធ្វើបាន) ដើម្បីបម្រើដល់ទស្សនវិស័យវែងឆ្ងាយ ក្នុងការត្រួសត្រាយផ្លូវឱ្យអ្នកបន្តវេនបន្តទទួលខុសត្រូវលើជោគវាសនាប្រទេសជាតិ និងប្រជាជន ដោយគ្មានស្ទាក់ស្ទើរ និងមិនចុះចាញ់ចំពោះឧបសគ្គ។

លោក ហ៊ុន ម៉ានី បានបញ្ជាក់ថា ៖ «ការបន្តវេន មុន និងក្រោយគង់តែត្រូវមកដល់ក៏ពិតមែន តែច្បាស់ណាស់ថា ក្រោមការដឹកនាំរបស់បងប្រុស ហ៊ុន ម៉ាណែត ជានាយករដ្ឋ














មន្ត្រី រាជរដ្ឋាភិបាលនឹងនៅតែបន្តបម្រើដោយស្មោះស្ម័គ្រចំពោះជាតិ និងប្រជាជន ឥតងាករេ និងមានតែប្រឹងប្រែងទ្វេដងថែមទៀត»។

ទន្ទឹមនឹងនេះដែរ លោក ហ៊ុន ម៉ានី ក៏បានបង្ហាញនូវការជឿទុកចិត្តចំពោះនាយករដ្ឋមន្ត្រី គឺលោក ហ៊ុន ម៉ាណែត ដែលជាបងប្រុសបង្កើតរបស់លោកផងដែរថា ៖ «បងណែត! ពួកយើងជឿជាក់លើបង!»

រួមជាមួយគ្នានេះដែរ លោក ស សុខា រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ក៏បានលើកឡើងដែរថា សេចក្តីថ្លែងសារពិសេសរបស់សម្តេចតេជោ ហ៊ុន សែន ប្រធានគណបក្សប្រជាជនកម្ពុជា និងការសម្រេចជាឯកច្ឆ័នរបស់ឥស្សរជនជាថ្នាក់ដឹកនាំគណបក្សពិសេស ព្រះរាជតម្រិះរិះដ៏ខ្ពង់ខ្ពស់បំផុតរបស់ព្រះមហាក្សត្រ គឺជារៀបចំផែនការជាតិដ៏គត់មត់ប្រកបដោយទស្សនាទានវែងឆ្ងាយគ្រប់ជ្រុងជ្រោយ។

លោកបានបញ្ជាក់ថា ៖ «ទន្ទឹមនឹងការគោរពនូវសេចក្តីថ្លែងសារដ៏សំខាន់បំផុតសម្រាប់ជាតិ ខ្ញុំ និងគ្រួសារ ព្រមទាំងក្រុមការងារ សូមសម្តែងនូវគារវកិច្ចប្រតិបត្តិតាមយ៉ាងខ្ជាប់ខ្ជួននូវការចាត់តាំង ឯកឧត្តម បណ្ឌិត ហ៊ុន ម៉ាណែត ជាបេក្ខជននាយករដ្ឋមន្ត្រី ដើម្បីរៀបចំសមាសភាពគណៈរដ្ឋមន្ត្រីថ្មីមួយទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភានាពេលខាងមុខដ៏ខ្លីនេះ»។

លោក គិន ភា ប្រធានវិទ្យាស្ថានទំនាក់ទំនងអន្តរជាតិនៃរាជបណ្ឌិតសភា ក៏បានលើកឡើងដែរថា ការបន្តវេនរបស់លោក ហ៊ុន ម៉ាណែត ជាការផ្ទេរដំណាក់កាលប្រវត្តិសាស្ត្រដ៏សំខាន់បំផុតនៃប្រទេសកម្ពុជានាសតវត្សរ៍ទី២១។

លោកថា ៖ «ការប្រកាសដ៏គួរឱ្យភ្ញាក់ផ្អើលរបស់សម្តេចតេជោ ហ៊ុន សែន នារសៀលថ្ងៃទី ២៦ ខែកក្កដា បានបង្កើតនូវភាពច្បាស់លាស់មួយនៃផែនការបន្តវេនដែលរៀបចំឡើងយ៉ាងល្អឥតខ្ចោះរបស់គណបក្សប្រជាជនកម្ពុជា ដោយគោរពទៅតាមលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់គណបក្ស និងគោលការណ៍ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យផងដែរ»។

ក្នុងប្រវត្តិសាស្ត្រជាង៥០០ឆ្នាំមកនេះ កម្ពុជាមិនដែលមានការផ្ទេរអំណាចឬការបន្តវេនប្រកបដោយសន្តិភាពនិងសេចក្តីស្ងប់សុខម្តងណាទេ។

លោក គិន ភា បានបន្ថែម ដោយលោកបញ្ជាក់ផងដែរថា ប្រទេសដ៏កម្សត់មួយនេះពើបប្រទះតែសង្គ្រាមដណ្តើមអំណាច ចលាចលសង្គម ការបែកបាក់ជាតិ និងការរស់ក្រោមនឹមត្រួតត្រាបរទេស ដែលកើតមានស្ទើរគ្រប់ដំណាក់កាលនៃប្រវត្តិសាស្ត្រ, ជាពិសេស ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៧០-១៩៨០ ប្រវត្តិសាស្ត្រកម្ពុជាចារដោយភ្នំឆ្អឹង ស្ទឹងឈាម និងសមុទ្រទឹកភ្នែកនៃប្រជាជនខ្មែរ។

លោកសង្កត់ធ្ងន់ថា ៖ «ពេលនេះ ជាងពេលណាៗទាំងអស់ ដែលប្រជាជាតិកម្ពុជាទាំងមូល គាំទ្រ អបអរសាទរ និងមានសេចក្តីសប្បាយរីករាយយ៉ាងក្រៃលែងចំពោះការអនុវត្តផែនការបន្តវេននៃមគ្គុទេសក៍ជាតិដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រជាង៥០០ឆ្នាំ ហើយដែលឆ្លើយតបទៅនឹងឆន្ទៈរបស់ប្រជាពលរដ្ឋនិងសំណូមពរនៃសភាពការណ៍សង្គមនិងនយោបាយ»។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន នាយប់ថ្ងៃទី២៦ ខែកក្កដា បានសរសេរលើបណ្តាញសង្គមធ្វីតធីរបស់លោកថា ៖ «ពេលកូនក្លាយជានាយករដ្ឋមន្ត្រីរបស់កម្ពុជា កូនត្រូវតែការពារឱ្យខាងតែបាននូវសន្តិភាពដើម្បីធានាដល់ការអភិវឌ្ឍ និងភាពសុខសាន្តរបស់ប្រជាជន»។

ចំណែក លោកបណ្ឌិត ហ៊ុន ម៉ាណែត បានសរសេរនៅលើបណ្តាញសង្គមហ្វេសប៊ុក និងតេលេក្រាម នារសៀលថ្ងៃទី២៧ ខែកក្កដាថា៖ «បណ្តាំរបស់ពុកដែលកូននឹងចងចាំជានិច្ច និងប្តេជ្ញាអនុវត្តឱ្យបានដាច់ខាតនៅក្នុងគ្រប់កាលៈទេសៈ៖ ពេលកូនក្លាយជានាយករដ្ឋមន្ត្រីរបស់កម្ពុជា កូនត្រូវតែការពារឱ្យខាងតែបាននូវសន្តិភាព ដើម្បីធានាដល់ការអភិវឌ្ឍ និងភាពសុខសាន្តរបស់ប្រជាជន»៕

## ជីវប្រវត្តិសង្ខេបលោក ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីថ្មីនៃកម្ពុជា

លោក ហ៊ុន ម៉ាណែត បានចាប់កំណើតនាថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៧ នាភូមិកោះថ្ម ស្រុកមេមត់ ខេត្តកំពង់ចាម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលគ្រប់គ្រងដោយខ្មែរក្រហម។

លោកជាកូនប្រុសច្បងរបស់ សម្តេចតេជោ ហ៊ុន សែន និងលោកស្រី ប៊ុន រ៉ានី លោក ហ៊ុន ម៉ាណែត បានសិក្សានៅសាលាបឋមសិក្សា និងអនុវិទ្យាល័យចតុមុខ ពីឆ្នាំ១៩៨០ដល់ឆ្នាំ ១៩៩០ ហើយពីឆ្នាំ១៩៩០ដល់១៩៩៣ លោកសិក្សានៅវិទ្យាល័យព្រះស៊ីសុវត្ថិ។

នៅឆ្នាំ១៩៩៤ លោក បានចូលបម្រើការងារក្នុងកងយោធពលខេមរភូមិន្ទ ហើយលោកក៏បានចូលសិក្សានៅសាលាយោធាសហរដ្ឋអាមេរិក West Point ផងដែរ។

នៅឆ្នាំ១៩៩៩ លោក ហ៊ុន ម៉ាណែត បានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត ដែលលោកជានិស្សិតកម្ពុជាដំបូងគេនៃបណ្ឌិត្យសភាអាម៉េរិក។ នៅឆ្នាំ២០០២ លោកបានទទួលសញ្ញាប័ត្រអនុបណ្ឌិតផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យញូវយ៉កសហរដ្ឋអាមេរិក។ នៅឆ្នាំ២០០៨ លោកបានទទួលសញ្ញាប័ត្របណ្ឌិតផ្នែកសេដ្ឋកិច្ចពីសាកលវិទ្យាល័យ Bristol ចក្រភពអង់គ្លេស។

នៅខែមករា ឆ្នាំ២០១១ លោក ហ៊ុន ម៉ាណែត បានក្លាយជាឧត្តមសេនីយឯក បន្ទាប់ពីលោកត្រូវបានតែងតាំងជាអគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជានាយរងសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ។

លោក ហ៊ុន ម៉ាណែត ក៏បានទទួលតួនាទីសំខាន់ៗមួយចំនួនទៀតជាបន្តបន្ទាប់ រហូតដល់ឆ្នាំ ២០២១ លោកត្រូវបានគណៈកម្មាធិការកណ្តាលរបស់គណបក្សប្រជាជនកម្ពុជា ជ្រើសរើសដោយការបោះឆ្នោតជាឯកច្ឆ័ន្ទ ជាបេក្ខភាពនាយករដ្ឋមន្ត្រីអនាគត។

នៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣ លោកត្រូវបានតម្លើងឋានៈជាឧត្តមសេនីយ៍ផ្កាយបួនជាផ្លូវការ ហើយនៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៣ លោកត្រូវបានព្រះមហាក្សត្រត្រាស់បង្គាប់តែងតាំងជានាយករដ្ឋមន្ត្រីកម្ពុជាជាផ្លូវការ៕



# គណបក្សកាន់អំណាចទទួលបានជ័យជំនះរហូតដល់ ១២០អាសនៈ

> «...ប្រជាជនបានបង្ហាញនូវភាពចាស់ទុំខាងនយោបាយក្នុងដំណើរការប្រជាធិបតេយ្យរបស់ខ្លួន ដោយទៅចូលរួមបោះឆ្នោតយ៉ាងច្រើនកុះករដែលសម្រេចបានខ្ពស់បំផុតក្នុងរយៈពេល២ទសវត្សរ៍ចុងក្រោយនេះ»

*អត្ថបទ៖ អមរិទ្ធ ដានុត*

ក្នុងការបោះឆ្នោតជាតិជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៧ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ កន្លងទៅនេះ គណបក្សប្រជាជនកម្ពុជា គណបក្សប្រជាជនកម្ពុជាទទួលបានសំឡេងឆ្នោតគាំទ្រចំនួន ៦ ៣៩៨ ៣១១១សំឡេង និងគណបក្សហ៊្វុនស៊ិនប៉ិចទទួលបានសំឡេងគាំទ្រចំនួន ៧១៦ ៤៩០សំឡេង។

នេះបើយោងតាមលទ្ធផលបណ្ដោះអាសន្នដែលបានចេញផ្សាយដោយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ខណៈដែលលទ្ធផលផ្លូវការនៃការបោះឆ្នោតនឹងត្រូវប្រកាសផ្សាយនៅចន្លោះពីថ្ងៃទី៩ ខែសីហា ដល់ថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ (តាមករណីគ្មាន ឬមានពាក្យបណ្ដឹង និងករណីគ្មានការបោះឆ្នោតសាជាថ្មី)។

តាមការគណនាក្រៅផ្លូវការនៃតារាងលទ្ធផលបោះឆ្នោតបណ្ដោះអាសន្ននេះបញ្ជាក់ថា គណបក្សប្រជាជនកម្ពុជាទទួលបានអាសនៈចំនួន ១២០ និងគណបក្សហ៊្វុនស៊ិនប៉ិច ទទួលបានអាសនៈចំនួន ៥ ដែលមាន៖ រាជធានីភ្នំពេញ១អាសនៈ, ខេត្តកណ្ដាល១អាសនៈ, កំពង់ធំ ១អាសនៈ, ព្រៃវែង ១អាសនៈ និងខេត្តកំពង់ចាម ១អាសនៈ។

លោក នុត សុខុម អនុប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានថ្លែងឱ្យដឹងថា ការិយាល័យបោះឆ្នោតទាំង ២៣ ៧៨៩ ការិយាល័យ បានបើកដំណើរដោយរលូន ដោយពុំមានការរាំងស្ទះ ឬពន្យារពេលនោះឡើយ។

លោកបានថ្លែងថា ៖ «អ្នកដែលបានទៅបោះឆ្នោតមានចំនួន ៨ ២១៣ ២៦០នាក់ ស្មើនឹង ៨៤,៥៨% នៃអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចំនួន ៩ ៧១០ ៦៥៥ នាក់ ហើយការបោះឆ្នោតនេះដែរប្រព្រឹត្តទៅដោយបរិយាកាសល្អប្រសើរ មិនមានអំពើហឹង្សា ឬភាពមិនប្រក្រតីណាមួយរារាំងក្នុងដំណើរការបោះឆ្នោតនោះឡើយ»។

យោងតាមសេចក្តីប្រកាសរបស់គ.ជ.ប ថា លទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតនេះមានសុពលភាពចាប់ពីថ្ងៃទី១ ខែសីហា តទៅ។

គ្រប់គណបក្សនយោបាយ ដែលបានឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៧ ឆ្នាំ ២០២៣ តាមមណ្ឌលរាជធានីខេត្ត អាចប្ដឹងតវ៉ាពីលទ្ធផលមួយផ្នែក ឬលទ្ធផលទាំងអស់នៃការបោះឆ្នោត ទៅគ.ជ.ប ឬទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៧២ ម៉ោងយ៉ាងយូរ បន្ទាប់ពីការប្រកាសលទ្ធផលប ណ្ដោះអាសន្នថ្ងៃទី១ ខែសីហា ឆ្នាំ២០២៣ ។

**ទស្សនៈពីបណ្ដាគណបក្សនយោបាយនានាចំពោះដំណើរការ និងលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតឆ្នាំ២០២៣**

សម្ដេចនាយករដ្ឋមន្ត្រីហ៊ុនសែនបានលើកឡើងថា ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ គឺជាការបោះឆ្នោតបំបែកនូវឯកតកម្មដែលបានរៀបចំកន្លងទៅ នោះគឺនៅត្រង់ថា បើទោះបីជាមានការញុះញង់ បង្កចលាចលរារាំងប្រជាជនមិនឱ្យទៅបោះឆ្នោតក៏ដោយ ប៉ុន្តែអត្រានៃការបោះឆ្នោតមានរហូតដល់៨៤,៥៨% ។

ក្នុងអត្រានៃអ្នកបានទៅបោះឆ្នោតនាថ្ងៃទី ២៣ ខែកក្កដា ឆ្នាំ២០២៣កន្លងទៅនេះ អ្នកដែលបានបោះជូនគណបក្សប្រជាជនកម្ពុជាមានអត្រារហូត៨២,៣០% គឺមានការកើនឡើងជាង១លានសម្លេង បើប្រៀបធៀបជាមួយនឹងការបោះឆ្នោតថ្នាក់ឃុំសង្កាត់ក្នុងឆ្នាំ២០២២ ។

បើប្រៀបធៀបទៅនឹងការបោះឆ្នោតនៅឆ្នាំ ២០១៣ គឺពេលនោះមានតែអត្រា៦៩,៦១% ប៉ុណ្ណោះ និងការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០១៨ មានត្រឹមតែ៨៣,០២% និងការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០២២មានចំនួនត្រឹមតែ៨០,៣២% ។

សម្ដេចមានប្រសាសន៍ថា ៖ «ជាមួយនឹងការប្រឆាំងនឹងការបោះឆ្នោត ដែលជាដំណើរការធម្មតានៃលទ្ធិប្រជាធិបតេយ្យរបស់ប្រជាជន ហើយក៏ចាត់ទុកជាថ្ងៃបុណ្យរបស់ប្រជាជនដើម្បីជ្រើសរើសមេដឹកនាំរបស់ខ្លួន តាមរយៈគណបក្សនយោបាយដែលចូលរួមការបោះឆ្នោត»។






សម្តេច ហ៊ុន សែន បានបន្តថា ៖ «យើងឃើញថាប្រជាជនបានបង្ហាញនូវភាពចាស់ទុំខាងនយោបាយក្នុងដំណើរការប្រជាធិបតេយ្យរបស់ខ្លួន ដោយទៅចូលរួមបោះឆ្នោតយ៉ាងច្រើនកុះករដែលសម្រេចបានខ្ពស់បំផុតក្នុងរយៈពេល ២ទសវត្សរ៍ចុងក្រោយនេះ»។

ប្រធានគណបក្សប្រជាធិតេយ្យមូលដ្ឋាន (គ.ប.ម) លោក យ៉េង វីរៈ បានប្រកាសទទួលស្គាល់ចំពោះលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ នេះដែរ និងប្រកាសផ្អេរការតស៊ូមតិដើម្បីលទ្ធិប្រជាធិបតេយ្យជូនអ្នកជំនាន់ក្រោយ។

លោក យ៉េង វីរៈ បានថ្លែងថា ៖ «លទ្ធផលបោះឆ្នោតបឋម បានចេញហើយ ខ្ញុំបានឃើញ និងគោរពទទួលស្គាល់ការសម្រេចចិត្តរបស់បងប្អូនម្ចាស់ឆ្នោត។ ដូចបានជម្រាបជូនកន្លងមកគ.ប.ម គ្រាន់តែបង្កើតជាជម្រើសជូនបងប្អូនប៉ុណ្ណោះ ព្រោះវាជាផ្លូវតែមួយគត់ដែលឱ្យយើងអាចដោះស្រាយបញ្ហា និងស្រោចស្រង់ដំណើរការប្រជាធិបតេយ្យនៅកម្ពុជា»។

ទោះប្រជាពលរដ្ឋ មិនបានបោះឆ្នោតគាំទ្រឱ្យជាប់ជាតំណាងរាស្ត្រនៅរដ្ឋសភាក៏ដោយ ក៏លោកមិនមានការខកចិត្ត ខកបំណងអ្វីដែរ។ នេះបើតាមការបន្ថែមពីលោក យ៉េង វីរៈ។

សម្រាប់ ប្រធានគណបក្សយុវជនកម្ពុជា លោក ពេជ្រ ស្រស់ ក៏បានទទួលស្គាល់ និងបង្ហាញការពេញចិត្តចំពោះលទ្ធលផលនៃការបោះឆ្នោតកាលពីថ្ងៃទី២៣ ទោះបីលោកមិនទទួលបានអាសនៈនៅក្នុងរដ្ឋសភាក៏ដោយ តែលោកថា សម្លេងគាំទ្រគណបក្សលោកមានការកើតឡើងជាលំដាប់ដែរ ចាប់តាំងពីចូលរួមការបោះឆ្នោតកាលពីឆ្នាំ ២០១៧មក។

ចំណែកគណបក្សខ្មែររួបរួមវិញ ក៏បានចេញសេចក្តីថ្លែងការណ៍ ប្រកាសគាំទ្រលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ដោយបានលើកឡើងថា ៖ «គណបក្សខ្មែររួបរួម សូមគាំទ្រលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ ដែលបានរៀបចំដោយគ.ជ.ប ដែលបានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ យុត្តិធម៌ ស្របតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងអាចទទួលយកបាន»។

### ការអបអរសាទរពីបណ្តាប្រទេសជាមិត្ត

លោក Nguyen Phu Trung អគ្គលេខាធិការគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តវៀតណាម បានផ្ញើសារអបអរសាទរ ដល់ប្រធានគណបក្សប្រជាជនកម្ពុជា សម្តេចតេជោ ហ៊ុន សែន ចំពោះជោគជ័យនៅក្នុងការបោះឆ្នោតជាតិជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ ឆ្នាំ២០២៣ នេះ ដែលលទ្ធផលនេះ បានបញ្ជាក់ ពីតួនាទី និងកិត្យានុភាពរបស់គណបក្សប្រជាជនកម្ពុជា។

ចំណែក ឯកអគ្គរដ្ឋទូតចិនប្រចាំនៅកម្ពុជា លោក វ៉ាង វិនធាន ក៏បានថ្លែងផងដែរថា ការបោះឆ្នោតនៅកម្ពុជា មានយុត្តិធម៌ មិនលម្អៀង ប្រជាពលរដ្ឋកម្ពុជា បានប្រើប្រាស់សិទ្ធិបោះឆ្នោតដោយសេរី ហើយក្នុងនាមជាមិត្តដែកថែបរបស់កម្ពុជា ប្រទេសចិនសូមចូលរួមអបអរយ៉ាងកក់ក្តៅ ចំពោះប្រទេសកម្ពុជា ដែលរៀបចំការបោះឆ្នោតប្រកបដោយជោគជ័យ ។

ប្រធានាធិបតីចិន លោក ស៊ី ជិនពីង រួមទាំងថ្នាក់ដឹកនាំរបស់ប្រទេសចិន ក៏បានចេញសារអបអរផងដែរពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ក្នុងប្រទេសកម្ពុជា ដែលទទួលបានជោគជ័យ ខណៈការបោះឆ្នោតនេះ ប្រទេសចិន ក៏បានបញ្ជូនអ្នកសង្កេតការណ៍មកចូលរួមសង្កេតផងដែរ។

រដ្ឋាភិបាលនៃការផ្សះផ្សាជាតិនិងឯកភាពជាតិនីការ៉ាហ្គា ក៏បានផ្ញើសារលិខិតសាទរចំពោះជោគជ័យនៅក្នុងការបោះឆ្នោតជាតិជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៧ កាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣ កន្លងទៅនេះដែរ។

សារលិខិតបានលើកឡើងថា ៖ «យើងខ្ញុំសូមថ្លែងអំណរសាទរជូនចំពោះសម្តេច ប្រធានគណបក្សប្រជាជន ក្នុងឱកាសដែលសម្តេច ទទួលបានជោគជ័យនៃការបោះឆ្នោតដែលបានប្រព្រឹត្តទៅនៅថ្ងៃអាទិត្យកន្លងទៅ ដោយមានចំនួន អ្នកចូលរួមបោះឆ្នោត ៨៤.២%»។





បណ្តាប្រទេសជាមិត្ត មួយចំនួនទៀត ក៏បានចូលរួមអបអរពីដំណើរការ និងលទ្ធផលនៃការបោះឆ្នោតនៅកម្ពុជា នាឆ្នាំ២០២៣ នេះផងដែរ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បានប្រកាសឱ្យដឹងថា អនុលោមតាមមាត្រា ១៣១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចែងថា បន្ទាប់ពីការប្រកាសលទ្ធផលបណ្តោះអាសន្ន ក្នុងរយៈពេល ៧២ ម៉ោងយ៉ាងយូរ គ្រប់គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត អាចប្តឹងតវ៉ាអំពីលទ្ធផលមួយផ្នែក ឬលទ្ធផលទាំងអស់នៃការបោះឆ្នោតមក គ.ជ.ប ឬទៅក្រុមប្រឹក្សាធម្មនុញ្ញ ដោយផ្ទាល់ក៏បាន។

ចំពោះការប្រកាសលទ្ធផលផ្លូវការ ការបែងចែកអាសនៈ និងការកំណត់បេក្ខជនជាប់ឆ្នោត នឹងប្រព្រឹត្តទៅនៅចន្លោះពីថ្ងៃទី៤ ខែសីហា ឆ្នាំ២០២៣ ទៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ អាស្រ័យករណីមាន ឬគ្មានពាក្យបណ្តឹង និងករណីគ្មានការបោះឆ្នោតសាជាថ្មី៕

## រថយន្ត Mercedes ដំបូងគេបង្អស់



កាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ ១៨៨៦ លោក Carl Benz បានដាក់ពាក្យសុំប៉ាតង់សម្រាប់រថយន្តបំពាក់ដោយម៉ាស៊ីនហ្គាសរបស់គាត់។ ប៉ាតង់ លេខ ៣៧៤៣៥ អាចត្រូវបានចាត់ទុកថាជាសំបុត្រកំណើតរបស់រថយន្ត។ នៅខែកក្កដាឆ្នាំ ១៨៨៦ សារព័ត៌មានបានរាយការណ៍អំពីការចេញលក់ជាសាធារណៈលើកដំបូងនៃរថយន្តម៉ាក Benz Patent Motor Car ដែលត្រូវបានផលិតឡើងដំបូងមានកង់ចំនួនបីគ្រាប់៕

## ដងបំផ្ទុះបំពង់ឫស្សី ដូនតានៃ «កាំភ្លើង»



អាវុធ (កាំភ្លើង) ត្រូវបានគេជឿថា ឃើញមាននៅសតវត្សរ៍ទី១០តរៀងមកនៅឯប្រទេសចិន។ ជនជាតិចិនសម័យបុរាណគឺជាមនុស្សដំបូងគេដែលបង្កើតរំសេវផ្ទុះ ដែលត្រូវបានអ្នកប្រវត្តិសាស្ត្របានចាត់ទុកថាអាវុធ (កាំភ្លើង) ខណៈជនជាតិចិនសម័យនោះហៅថាដងផ្ទុះ វាជាដុំលោហៈ ជាដែក ឬក៏បំពង់ឫស្សីដែលផ្ទុករំសេវ សំរាប់បំផ្ទុះ សម្រាប់ភ្ជាប់នឹងចុងលំពែងដំបង។ រហូតដល់ក្រោយមក គេបានវិវឌ្ឍន៍វាក្លាយជាកាំភ្លើងបន្តិចម្តងៗតាមយុគសម័យក្រោយមកទៀត។

## រូបថតដំបូងគេបំផុតក្នុងប្រវត្តិសាស្ត្រមនុស្ស

លោក Joseph Nicéphore Niépce (៧មីនា ១៧៦៥ - ៥ កក្កដា ១៨៣៣) បានថតរូបដំបូងបំផុតរបស់ពិភពលោកក្នុងឆ្នាំ១៨២៦ ដោយប្រើម៉ាស៊ីនថតរូបប្រអប់ឈើផលិតឡើងដោយលោក Charles និង Vincent Chevalier។ លោកបានថតរូបភាពនេះពីបង្អួចជាន់លើនៃអគាមួយក្នុងប្រទេសបារាំង។





# ប្រទេសណាផលិតគ្រាប់ គ្រាប់មីស៊ីល មុនគេ?



*ប្រភព៖ សារព័ត៌មានហ្វ្រេសញ៊ីវ*

មីស៊ីល គឺជាប្រភេទសព្វាវុធមួយដែលគេប្រើប្រាស់សម្រាប់ការវាយប្រហារពីចម្ងាយ ដោយវាអាចហោះបានដោយខ្លួនឯង។ សព្វថ្ងៃនេះវាមានទម្រង់ជាច្រើនប្រភេទ រួមមានចាប់តាំងពីមីស៊ីលធម្មតាៗ រហូតដល់មីស៊ីលផ្លោងដែលអាចបំពាក់ក្បាលគ្រាប់នុយក្លេអ៊ែរ និងអាចហោះឆ្លងទ្វីបបាន។

មីស៊ីល ដំបូងបំផុតដែលត្រូវបានប្រើប្រាស់ក្នុងប្រតិបត្តិការ គឺពពួកមីស៊ីល ដែលអភិវឌ្ឍឡើងដោយយោធាអាល្លឺម៉ង់ កាលពីសង្គ្រាមលោកលើកទីពីរ។ ក្នុងចំណោមនោះ មីស៊ីល ដែលគេស្គាល់ច្រើនគឺមីស៊ីល V-1 និង V-2។ យ៉ាងណាមិញ មីស៊ីល ជំនាន់ដំបូងដែលត្រូវបានប្រើប្រាស់នៅក្នុងសម័យនោះ គឺត្រូវបានផលិតឡើងក្នុងចំនួនតិចតួចប៉ុណ្ណោះ ហើយមិនសូវមានប្រសិទ្ធភាពប៉ុន្មាននោះទេ។

បច្ចុប្បន្ន មីស៊ីល មានសមាសធាតុផ្សំសំខាន់ៗ ដូចជាមានប្រព័ន្ធនាំផ្លូវ ប្រព័ន្ធហោះហើរ ម៉ាស៊ីន និងក្បាលគ្រាប់ជាដើម។ ប្រព័ន្ធនាំផ្លូវ គឺមានសារសំខាន់ជាខ្លាំងសម្រាប់មីស៊ីលនីមួយ។ មីស៊ីល ខ្លះអាចបំពាក់នូវឧបករណ៍ស្ទាបស្ទង់ប្រភេទអ៊ីនហ្វ្រារេដ (Infrared) ដើម្បីដេញតាមចំហាយកម្ដៅដែលភាយចេញពីម៉ាស៊ីនយន្តហោះ ចំណែកមីស៊ីល ខ្លះទៀត ត្រូវបាននាំផ្លូវទៅកាន់គោលដៅវាយប្រហាររបស់វា តាមរយៈការចង្អុលបង្ហាញពីប្រព័ន្ធឡាស៊ែររបស់កងទ័ពថ្មើរជើងនៅក្បែរគោលដៅផ្ទាល់ជាដើម។

ជាទូទៅ មីស៊ីល ត្រូវគេចាត់ថ្នាក់ចេញជាប្រភេទមួយចំនួនសម្រាប់បម្រើគោលដៅខុសៗគ្នា ដូចជា ប្រភេទបាញ់ពីផ្ទៃដីទៅកាន់ផ្ទៃដី (Surface-to-Surface) បាញ់ពីផ្ទៃដីទៅកាន់ផ្ទៃអាកាស (Surface-to-Air) បាញ់ពីផ្ទៃអាកាសទៅកាន់ផ្ទៃដី (Air-to-Surface) និងប្រភេទបាញ់ពីផ្ទៃអាកាសទៅកាន់ផ្ទៃអាកាស (Air-to-Air) ផងដែរ។

សម្រាប់ប្រភេទមីស៊ីល បាញ់ពីផ្ទៃដីទៅកាន់ផ្ទៃដី ភាគច្រើនគឺមីស៊ីលផ្លោង ឬហៅថាមីស៊ីល បាលីស្ទិក ដែលបាញ់ចេញពីផ្ទៃដី និងពីនាវាមុជទឹកឱ្យឆ្លងផុតបរិយាកាសផែនដី ហើយធ្លាក់ទៅរកគោលដៅនៅលើផ្ទៃដី ដោយប្រើកម្លាំងទំនាញ។ ចំណែកប្រភេទមីស៊ីល បាញ់ពីផ្ទៃអាកាសទៅកាន់ផ្ទៃដី រួមមានមីស៊ីល គ្រូស (Cruise Missile) ដែលហោះហើរក្នុងរយៈកម្ពស់ទាបក្នុងគោលដៅប្រឆាំងនាវា ឬរថក្រោះជាដើម។ សម្រាប់ប្រភេទមីស៊ីល បាញ់ពីផ្ទៃដីទៅកាន់ផ្ទៃអាកាស ជាពួកមីស៊ីល ដែលគេប្រើដើម្បីប្រឆាំងយន្តហោះ និងមីស៊ីល ផ្លោង។ រីឯប្រភេទមីស៊ីលបាញ់ពីផ្ទៃអាកាសទៅកាន់ផ្ទៃអាកាស ជាមីស៊ីល លធម្មតាៗដែលបំពាក់នៅក្នុងយន្តហោះចម្បាំង ប្រើប្រាស់សម្រាប់បាញ់យន្តហោះដូចគ្នា។ បន្ថែមពីនេះ ក៏មានប្រភេទមីស៊ីល ដែលគេបាញ់ឱ្យរត់នៅក្រោមផ្ទៃទឹកផងដែរ ដែលគេហៅថា ថរភីដូ (Torpedo)។

ក្រៅពីប្រភេទទាំងអស់នេះ ក៏នៅមានប្រភេទមីស៊ីល សម្រាប់ប្រឆាំងផ្កាយរណប និងពពួកមីស៊ីល លឿនជាងសំឡេងខ្លាំង (Hypersonic Missile) ហើយមានតែប្រទេសមហាអំណាចដូចជាសហរដ្ឋអាមេរិក រុស្ស៊ី ចិន និងឥណ្ឌាប៉ុណ្ណោះដែលមានវានៅក្នុងដៃ៕











# ឆមាសទី១ដើមឆ្នាំ ការនាំចេញក៏ធ្លាក់រីឯការនាំចូលក៏ធ្លាក់ចុះ

*អត្ថបទ៖ អរិយក្សត្រ*

នៅឆមាសទីមួយដើមឆ្នាំ២០២៣ នេះ ស្ថានភាពពាណិជ្ជកម្មកម្ពុជាធ្លាក់ចុះទាំងការនាំចេញ និងការនាំចូល ខណៈដែលពាណិជ្ជកម្មសរុបមានតម្លៃ ២៤,៨៩៦ លានដុល្លារ។



ពាក់ព័ន្ធនឹងបញ្ហានេះរបាយការណ៍ថ្មីមួយដែលចេញផ្សាយដោយធនាគារជាតិនៃកម្ពុជា បានអះអាងថា កា រនាំចេញរបស់កម្ពុជាមានតម្លៃប្រមាណជា ១១, ៤៨៩ លានដុល្លារធ្លាក់ចុះប្រមាណជា ២,១ ភាគរយ ស្របពេលដែលការនាំចូលគឺមានតម្លៃប្រមាណជា ១២, ៨៩៦ លានដុល្លារធ្លាក់ចុះ ២២,៤ ភាគរយ ។

ប្រភពដដែលបានអះអាងថា ការនាំចេញសម្លៀកបំពាក់ដែលគេដឹងថា ជាទំនិញនាំចេញដ៏ចំបងរបស់កម្ពុជានោះ គឺមានតម្លៃត្រឹមតែជាង ៣,៦៥៤ លានដុល្លារធ្លាក់ចុះប្រមាណជា ១៩ ភាគរយ ស្បែកជើងមានតម្លៃប្រមាណជា ៧០១ លានដុល្លារធ្លាក់ចុះ ប្រមាណជា ១៧,២ ភាគរយ សំភារៈសម្រាប់ធ្វើដំណើរ និងផលិតផលផ្សេងទៀត គឺមានតម្លៃត្រឹមតែ ៩៩៩ លានដុល្លារ ធ្លាក់ចុះ ១៧,១ភាគរយ កង់មានតម្លៃ ៣៣២ លានដុល្លារធ្លាក់ចុះ ៣០,៥ ភាគរយ។

ប៉ុន្តែការនាំចេញគ្រឿងអេឡិចត្រូនិច មានតម្លៃ ១, ៤៤០ លានដុល្លារកើនឡើង១,៣ ភាគរយ កៅស៊ូ មានតម្លៃ ១៦៤ លានដុល្លារធ្លាក់ចុះ ៩,៨ ភាគរយ តែអង្ករ គឺមានតម្លៃ ២២៩ លានដុល្លារកើនឡើង ១២,៤ភាគរយ។

ប្រភពដដែលបានឲ្យដឹងថា ការនាំចូលវិញត្រូវបានគេដឹងថា គឺការនាំចូលវត្ថុធាតុដើម មានតម្លៃសរុប ប្រមាណជា ២,១៥៧ លានដុល្លារធ្លាក់ចុះជិត ១៨ ភាគរយ រថយន្ត មានតម្លៃប្រមាណជា ៧១៧ លានដុល្លារធ្លាក់ចុះ ជិត ២៣ ភាគរយ។ ប្រេងឥន្ធនៈវិញមានតម្លៃ ២, ៣៦៩ លានដុល្លារធ្លាក់ចុះ ជិត២ភាគរយ តែការនាំចូលសំភារៈសំណង់មានតម្លៃ ៩១១ លានដុល្លារ កើនឡើងបន្តិចគឺ០,៤ ភាគរយ ខណៈដែលការនាំចូលអាហារនិងភេសជ្ជៈវិញ គឺមានតម្លៃសរុប ៦២៩ លានដុល្លារ កើនឡើង២,៣ភាគរយ។

ផ្អែកតាមរបាយការណ៍ដដែលនេះ នៅឆមាសទី១ ឆ្នាំ២០២៣ ទុនបម្រុងអន្តរជាតិកម្ពុជា បានកើនឡើងបន្តិច ពោលគឺ៣,២ ភាគរយ មានតម្លៃសរុបប្រមាណជា ១៨,៤ លានដុល្លារ។

នេះគឺជាស្ថានភាពពាណិជ្ជកម្ម និងទុនបម្រុង ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏សេដ្ឋកិច្ចកម្ពុជាស្ថិតនៅក្នុងស្ថានភាពទប់ទល់ដោយសារតែពន្ធគយ និងពន្ធដាមានស្ថានភាពវិជ្ជមាន។

ពាក់ព័ន្ធនឹងបញ្ហានេះ លោក ជា ចាន់តូ អគ្គទេសាភិបាលនៃធនាគារជាតិកម្ពុជា បានថ្លែងថា សេដ្ឋកិច្ចកម្ពុជានៅតែបន្តមានស្ថេរភាព ខណៈដែលកំណើនសេដ្ឋកិច្ចនៅក្នុងឆ្នាំនេះ អាចនឹងទទួលបាននៅក្នុងរង្វង់៥,៥ភាគរយ រីឯអត្រាអតិផរណាវិញ ត្រូវបានព្យាករថា នឹងថយចុះមកក្នុងរង្វង់២ភាគរយ ។

លោកបានអះអាងថា នៅក្នុងស្ថានភាពនេះ ធនាគារជាតិនៃកម្ពុជា នឹងបន្តអនុវត្តនយោបាយរូបិយវត្ថុ និងវិធានការម៉ាក្រូនិងមីក្រូសេដ្ឋកិច្ចនៅក្នុងស្ថានភាពប្រុងប្រយ័ត្ន ប្រកបដោយស្មារតីបុរេសកម្ម និងបត់បែន ទៅតាមការវិវត្តនៃសេដ្ឋកិច្ច ក្នុងគោលដៅរក្សាស្ថិតភាពថ្លៃនិងស្ថិរភាពហិរញ្ញវត្ថុ៕

# «ផ្ទះស្នាក់កេសរកូល» ចំណាយថវិកាជាង ១៦ម៉ឺនដុល្លារ បានដាក់ឱ្យប្រើប្រាស់



*អត្ថបទ៖ អមរិន្ទ ដានុត*

លោក សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានថ្លែងឱ្យដឹងថា ស្នាក់ការឧទ្យានុរក្ស ផ្ទះស្នាក់កេសរកូល និងហេដ្ឋារចនាសម្ពន្ធ័នានា នៅឧទ្យានជាតិព្រះជ័យវរ្ម័នភ្នំគូលែន ជាការទ្រទ្រង់គោលនយោបាយនាំចេញនៅនឹងកន្លែង សេដ្ឋកិច្ចគ្រួសារ និងទេសចរណ៍ផ្សារភ្ជាប់ទឹកដី។

លោកបានលើកឡើងដូចនេះ ក្នុងឱកាសដាក់សម្ពោធអោយប្រើប្រាស់ ស្នាក់ការឧទ្យានរក្ស និងផ្ទះស្នាក់កេសរកូល នៅឧទ្យានជាតិព្រះជ័យវរ្ម័ននរោត្តម ភ្នំគូលែន នៅខេត្តសៀមរាប នាថ្ងៃទី២ ខែសីហា ឆ្នាំ២០២៣ ។

លោកមានប្រសាសន៍ថា៖ «ការរៀបចំឧទ្យានជាតិឱ្យមានសណ្តាប់ធ្នាប់ និងរបៀបរៀបរយ តាមរយៈការកសាងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធដូចជាស្នាក់ការឧទ្យានុរក្ស ផ្ទះស្នាក់មជ្ឈមណ្ឌលកេសរកូល ផ្លូវ ទឹកស្អាត និងបង្គន់អនាម័យ»។

លោក សាយ សំអាល់ បានបន្តថា ផ្សារសហគមន៍ ដើម្បីបង្កើនប្រសិទ្ធិភាពនៃការគ្រប់គ្រងកិច្ចការពារ និងអភិរក្សធនធានធម្មជាតិ និងជីវៈចម្រុះ លើកកម្ពស់ការសិក្សាស្រាវជ្រាវ ការថែរក្សានិងអភិរក្សធនធានពិន្ទុ ការបម្រើឱ្យទេសចរណ៍ផ្សារភ្ជាប់នឹងទឹកដី និងការលើកកម្ពស់សេដ្ឋកិច្ចមូលដ្ឋាន និងការលើកកម្ពស់សុខមាលភាព និងសេចក្តីថ្លៃថ្នូររបស់មន្ត្រីឧទ្យានុរក្សក្នុងនាមជាឆ្មាំការពារព្រៃ។

សូមបញ្ជាក់ដែរថា ស្នាក់ការឧទ្យានុរក្សនេះបានសាងសង់ពី ខែសីហា ឆ្នាំ២០២២ និងរួចរាល់ជាស្ថាពរនៅ ខែឧសភាឆ្នាំ២០២៣ ចំណាយថវិកាអស់ចំនួន ១៦០,៦៨៥ ដុល្លារអាមេរិក គាំទ្រដោយក្រសួងបរិស្ថាន តាមរយៈ គម្រោង «និរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា» ។

ទីតាំងសាងសង់ ទីស្នាក់ការនេះ គឺជាចំណុចកណ្តាល ដែលអាចផ្តល់ភាពងាយស្រួលក្នុងការធ្វើដំណើររវាងស្រុកស្វាយលើ ស្រុកបន្ទាយស្រី និងទីរួមខេត្តសៀមរាប ជាពិសេស ដើម្បីសម្រួលដល់ការងារត្រួតពិនិត្យអ្នកធ្វើដំណើរឡើងចុះឧទ្យានជាតិ ព្រះជ័យវរ្ម័ន-នរោត្តម «ភ្នំគូលែន» ដែលមានផ្ទៃដីទំហំ ៣៧.៣៧៣ហិកតា។

វាជាតំបន់អាទិភាពមួយនៃតំបន់អេកូឡូស៊ីព្រៃស្រោង និងព្រៃពាក់កណ្តាលស្រោង ស្ថិតនៅរយៈកម្ពស់មធ្យមនិងទទួលរងអាកាសធាតុមូសុងដែលផ្តល់លក្ខខណ្ឌដល់ការលូតលាស់ជីវៈចម្រុះគ្រប់ប្រភេទ។



ក្រៅពីផ្ទះស្នាក់កេសរកូល ក្រសួងបរិស្ថាន ក៏បានកសាងហេដ្ឋារចនាសម្ព័ន្ធជាបន្តបន្ទាប់បន្ថែមទៀត នៅមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូលដូចជា សួនកេសរកូលពូជបង្កាត់ សួនមេអំបៅ សួនវ៉ាន់នីឡា សួនបន្លែធម្មជាតិ ហាងកាហ្វេ តូបលក់ផលិតផលធម្មជាតិ ស្តាប្រទ្បាយធម្មជាតិ តំឡើងថាមពលពន្លឺព្រះអាទិត្យកំលាំង ៣៣KW និងរៀបចំកសិដ្ឋានចិញ្ចឹមជ្រូកគូលែនជាដើម។

គួរបញ្ជាក់ថា៖ អាគារដែលបានដាក់សម្ពោធនេះ មានចំនួន៣ ជាប់គ្នា អាគារធំនៅចំកណ្តាល និងអាគារតូចៗចំនួន២ អមសងខាង នៅលើផ្ទៃដីសរុប ទំហំ១០ ហ.ត ស្ថិតក្នុងភូមិសាស្ត្រ ភូមិស្រះខ្វាវ ឃុំតៀង ស្រុកបន្ទាយស្រី (ទល់មុខសួនកេសរកូល) បានសាងសង់ចាប់ពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២២ ហើយបានបញ្ចប់ការសាងសង់ជាស្ថាពរនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២៣៕

# រលកកម្តៅជះឥទ្ធិពលដល់សុខភាពប្រជាជននៅអឺរ៉ុប



*អត្ថបទ៖ ផាត សំភី*

អង្គការឧតុនិយមអន្តរជាតិ (OMM) បានព្រមានថា គ្រោះថ្នាក់ពាក់ព័ន្ធនឹងរលកកម្តៅដែលបានកើតមានឡើងនៅអឌ្ឍគោលខាងជើងនៃភពផែនដីមិនទាន់បញ្ចប់ទេ។

នៅក្នុងការប្រកាសអាសន្ន ទីភ្នាក់ងារនៃអង្គការសហប្រជាជាតិ បានគូសបញ្ជាក់ថា រលកកម្តៅ គឺស្ថិតក្នុងចំណោមហានិភ័យធម្មជាតិដែលសម្លាប់បំផុត។ ទីប្រឹក្សាសំខាន់នៃអង្គការឧតុនិយមអន្តរជាតិ ខាងផ្នែកកម្តៅ លោក ចន ណែន បានប្រកាសថា កម្តៅក្តៅបំផុត ស្ថិតនៅលើចំនុច នៃការកើនឡើងជាញឹកញាប់ ទាំងរយៈពេលយូរ និងវិសាលភាព។ លោកបាននិយាយថា ៖ «សីតុណ្ហភាពពេលយប់កើនឡើងម្តងហើយម្តងទៀត មានគ្រោះថ្នាក់ជាពិសេសសម្រាប់សុខភាពមនុស្ស ដោយសារតែរាងកាយ មិនអាចសម្របសម្រួលនឹងសីតុណ្ហភាពបាន។ រឿងនេះនាំទៅដល់ការកើនឡើងនូវករណីគាំងបេះដូង និងការស្លាប់។»

យោងតាមរបាយការណ៍ថ្មីមួយនៃទីភ្នាក់ងារអង្គការសហប្រជាជាតិ មនុស្ស ៦០០០០នាក់ ថែមទៀត បានស្លាប់ដោយសារតែកម្តៅក្តៅខ្លាំង នៅអឺរ៉ុបកាលពីរដូវក្តៅមុន ទោះបីជាមានផែនការរឹងមាំក្នុងការព្រមានជាមុន និងសកម្មភាពសុខភាពដ៏ប្រសើរនៅទ្វីបនេះក៏ដោយ។

អង្គការឧតុនិយមពិភពលោក បានប្រកាសថា វាមានភាពបន្ទាន់ក្នុងការសម្របសម្រួលហេដ្ឋារចនាសម្ព័ន្ធដើម្បីតស៊ូប្រឆាំងនឹងកម្តៅខ្លាំងដែលបន្លាយពេល និងយកចិត្តទុកដាក់ចំពោះមនុស្សដែលងាយរងគ្រោះនឹងហានិភ័យ។

ទីភ្នាក់ងារនេះក៏បានព្រមានប្រឆាំងនឹងហានិភ័យដែលចេះតែកើនឡើងសម្រាប់ការស្លាប់ដោយសាររលកកម្តៅ នៅអាស៊ី អាហ្វ្រិកខាងជើង និងសហរដ្ឋអាម៉េរិក។

លោកណែន បានគូសបញ្ជាក់ថា ៖ «កម្តៅដែលក្លាយជាហានិភ័យសម្រាប់សុខភាព មានការកើនឡើងយ៉ាងរហ័សដោយសារហេតុផលនគរូបនីយកម្មកើនឡើង និងការកើនឡើងនូវសីតុណ្ហភាពខ្លាំងក្លា និងការឡើងវ័យចាស់របស់ប្រជាជន។»យោងតាមអង្គការឧតុនិយមពិភពលោកបានឲ្យដឹងទៀតថា រលកកម្តៅរីកសាយភាយ និងពង្រីកវិសាលភាពនៅឆ្នាំនេះ គឺជាការប្រកាសអាសន្ន។

លោក ណែន បានទទូចថា ៖ «លក្ខខណ្ឌដែលក្តៅចង់ឆេះ គឺមិនមែនជាប្រព័ន្ធឧតុនិយមធម្មតាកាលពីអតីតកាលនោះទេ។ វាគឺជា វិបាកនៃការប្រែប្រួលអាកាសធាតុ។ យើងបានបាត់បង់ទឹកកកនៅប៉ូលខាងជើង និងរឿងនេះបានពង្រឹងយន្តការកម្តៅកើនឡើង ហើយវានឹងបន្តទៅមុខទៀត»។

លោកប៉ាន្ទូ សាអារីស្ត្ល គឺជាប្រធានក្រុមនៃអង្គការសុខភាពបន្ទាន់នៃសហព័ន្ធអន្តរជាតិកាកបាទក្រហម និងអឌ្ឍចន្ទក្រហម។ លោក ប៉ាន្ទូ សាអារីស្ត្ល បានប្រកាសថា វាមានសារៈសំខាន់ចាំបាច់នឹងឃ្លាំមើលមនុស្សងាយរងគ្រោះដោយសារហេតុផលនៃសុខភាពមិនល្អរបស់ពួកគេ ប៉ុន្តែគេក៏ត្រូវយកចិត្តទុកដាក់លើលក្ខខណ្ឌសង្គមសេដ្ឋកិច្ច និងលក្ខខណ្ឌជីវិតដែលអាច នាំមកនូវហានិភ័យដូចគ្នា។

លោកប៉ាន្ទូ សាអារីស្ត្ល បានបន្ថែមថា សង្កាត់ដែលប្រជាជនមានចំណូលទាបនៅអឺរ៉ុបសព្វថ្ងៃរង់ផលប៉ះពាល់ខ្លាំងបំផុត។ លោកបានកត់សម្គាល់ថា រលកកម្តៅក៏មានឥទ្ធិពលលើវិស័យដទៃៗ ទៀតនៃសង្គមដោយសារហេតុផលនៃការថយចុះនៃផលិតផលសេដ្ឋកិច្ច។

អង្គការឧតុនិយមពិភពលោក បានបញ្ជាក់ថា នៅក្នុងពិភពលោកទាំងមូល ការកើនកម្តៅដែលធ្ងន់ធ្ងរបំផុត និងមិនអាចជៀសផុតបាន។ វាជាការបង្គាប់បញ្ជាឲ្យត្រៀមខ្លួន និងសម្របខ្លួនដោយសារទីក្រុងជាច្រើន ផ្ទះ និងកន្លែងធ្វើការមិនបានសាងសង់ឡើងដើម្បីតស៊ូនឹងសីតុណ្ហភាពដែលកើនក្តៅខ្លាំង និងបន្លាយរយៈពេលយូរនោះទេ៕

# សាកល្បងឆ្លើយ៖

តើអ្នកបើកបរត្រូវផ្តល់សិទ្ធិឱ្យរថយន្តណាទៅមុន? ប្រសិននៅលើផ្លូវប្រសព្វមានផ្លាកសញ្ញាចរាចរណ៍សម្គាល់ ដូចក្នុងរូបភាពខាងស្តាំនេះ។

*ដើម្បីទទួលបានព័ត៌មានបន្ថែម សូមតាមដានការចុះផ្សាយប្រចាំថ្ងៃ នៅលើហ្វេសប៊ុកក្រសួង ស្វែងយល់ពីច្បាប់ចរាចរណ៍ផ្លូវគោក ដើម្បីជាការចូលរួមចំណែកកាត់បន្ថយការកកស្ទះចរាចរណ៍ និងជួយទប់ស្កាត់គ្រោះថ្នាក់ចែជន្យ*

*-ទាញយក និងតម្លើងកម្មវិធី Cambodia Driving Rules ដោយអត់គិតថ្លៃ (FREE Download) ដើម្បីទទួលបានចំណេះដឹងល្អៗ ពីទ្រឹស្តីនៃការបើកបរ នៃច្បាប់ចរាចរណ៍ផ្លូវគោក៖*

- App Store (iOS): ***http://dr.mpwt.gov.kh/ios***
- Play Store (Android): ***http://dr.mpwt.gov.kh/android***







ចម្លើយដែលត្រឹមត្រូវ៖ ......៣......




ចម្លើយដែលត្រឹមត្រូវ៖ ......១......




ចម្លើយដែលត្រឹមត្រូវ៖ ......១......

# គ្រូអប់រំជំនឿ២មណ្ឌលសកម្មភាពទទួលមេរៀនអប់រំជំនឿបន្ថែម

*អត្ថបទ៖ ចាន់ ម៉ានុត*

ដើម្បីឱ្យគ្រូអប់រំជំនឿយល់ដឹងអំពីដើមកំណើតនឹងយល់ពីអត្ថន័យនៃពាក្យមួយម៉ាត់ៗរបស់ធម៌ប្រកាសជំនឿ ការិយាល័យអប់រំជំនឿបានរៀបចំសិក្ខាសាលាមួយដល់គ្រូអប់រំជំនឿនៃមណ្ឌលសកម្មភាពបាសាក់ និងមេគង្គ ក្រោមប្រធានបទ «កំណើតធម៌ប្រកាសជំនឿ»។



សិក្ខាសាលានេះ ធ្វើឡើងនៅព្រះវិហារសន្តហ្វ្រង់ស្វ័រ សាវីយេ៉(វត្តចំប៉ា) កាលពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣កន្លងទៅនេះ ដោយមានសិក្ខាកាមចូលរួមប្រមាណជា៤០នាក់។

លោកបូជាចារ្យ សុខ ណា ជាបូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពបាសាក់ បានប្រាប់ឱ្យដឹងថា ធម៌ប្រកាសជំនឿគឺជាធម៌គ្រឹះដែលគ្រីស្តបរិស័ទត្រូវតែជឿ ព្រោះជាសេចក្តីពិតដែលព្រះសហគមន៍ណែនាំតាំងពី២០០០ឆ្នាំ ដោយឱ្យគ្រីស្តបរិស័ទយកចិត្តទុកដាក់ប្រកាសជំនឿ។





លោកមានប្រសាសន៍ថា ៖ «ធម៌ប្រកាសជំនឿជាមធ្យោបាយ និងជាយានជំនិះដើម្បីឱ្យគ្រីស្តបរិស័ទផ្ញើជីវិតទាំងស្រុងទៅលើព្រះជាម្ចាស់ នៅពេលដែលពួកគេប្រកាស គឺពួកគេប្រើជីវិត ប្រើសម្លេងប្រើស្មារតី ទាំងព្រលឹងវិញ្ញាណដែលជឿលើព្រះជាម្ចាស់ណែនាំឱ្យពួកគេ មានជំនឿដោយខ្លួនឯង»។

លោកបូជាចារ្យបានបន្តថា ៖ «ត្រូវប្រកាសជំនឿដោយខ្លួនឯង ដើម្បីទៅដល់ព្រះជាម្ចាស់ ដើម្បីទៅដល់ប្រភពនៃជីវិតដែលរំពឹងទុកនៅថ្ងៃចុងក្រោយនៃជីវិតគឺទទួលការសង្គ្រោះ»។

ធម៌ប្រកាសជំនឿជាអត្តប្រយោជន៍របស់ព្រះសហគមន៍ ដែលត្រូវដឹងថាការរួមជាមួយព្រះសហគមន៍ដោយសារធម៌ ជឿណែនាំឱ្យគ្រប់គ្នាមានព្រះសហគមន៍ ជាសហភាពដែលជាផ្លុងតែមួយហើយដោយសារតែធម៌ណែនាំឱ្យគ្រីស្តបរិស័ទគ្រប់ទិសទីរួបរួមគ្នាជាសហភាពតែមួយ ជាផ្លុងតែមួយ និងដាក់ចិត្តផ្ញើជីវិតទាំងស្រុងលើព្រះជាម្ចាស់តែមួយដែលមានជំនឿតែមួយ និងចុងក្រោយទៅដល់ព្រះសហគមន៍នៅស្ថានបរមសុខ។ នេះបើយោងតាមការបញ្ជាក់ពីលោកបូជាចារ្យ សុខ ណា។



អ្នកគ្រូ គឹម សុភា អាយុ៤០ឆ្នាំ ជាគ្រូអប់រំជំនឿមកពីព្រះវិហារគង្វាលដ៏សប្បុរស(រោងចក្រ) នៃមណ្ឌលសកម្មភាពមេគង្គ បានប្រាប់ឱ្យដឹងដែរថា ក្នុងការបម្រើព្រះសហគមន៍ជិត២០ឆ្នាំមកនេះ អ្នកគ្រូគិតថាគាត់មានជំនឿរឹងមាំដើម្បីបញ្ជូនបន្តទៅដល់អ្នកឯទៀតៗបាន ប៉ុន្តែឆ្លងកាត់កម្មវិធីសិក្ខាសាលារយៈពេលមួយថ្ងៃនេះធ្វើឱ្យគាត់យល់ថានៅមានចំណុចខ្វះខាត។

អ្នកគ្រូបន្តថា ៖ «ធម៌ប្រកាសជំនឿជាធម៌បង្ហាញពីព្រះសហគមន៍ ពីជីវិតព្រះយេស៊ូយ៉ាងក្បោះក្បាយ ហើយយើងគ្រាន់តែសូត្រឱ្យចាំមាត់តែប៉ុណ្ណឹងដោយយើងមិនសូវចាប់អារម្មណ៍ប៉ុន្តែក្នុងសិក្ខាសាលានេះបានពន្យល់ណែនាំឱ្យជំនឿរបស់យើងរឹងមាំជាងមុន ហើយគោលសំខាន់របស់ធម៌ប្រកាសជំនឿដែលកម្មវិធីបានពន្យល់នឹងធ្វើឱ្យយើងយល់កាន់តែច្បាស់ជាងមុនដើម្បីបញ្ជូនបន្តទៅកាន់ប្អូនៗជំនាន់ក្រោយឱ្យស្គាល់ជីវិតរបស់ព្រះយេស៊ូ និងអត្ថន័យនៃឃ្លានីមួយៗដែលមាននៅក្នុងធម៌ប្រកាសជំនឿ»។

ដោយនេះជាលើកទីមួយដែលបានចូលរួមសិក្ខាសាលាគ្រូអប់រំជំនឿ លោក អ៊ី សៀវធាន ជាគ្រូអប់រំជំនឿមកពីព្រះវិហារសន្តយ៉ូសែប ជ្រៃធំ បានរៀបរាប់ថា លោកពិតជាមានអំណរសប្បាយយ៉ាងខ្លាំង។

លោកថា ការចូលរួមសិក្ខាសាលានេះធ្វើឱ្យលោកទទួលបានបទពិសោធន៍ថ្មីៗ ចំណេះដឹងបន្ថែមទាក់ទងជាមួយធម៌ប្រកាសជំនឿ យល់អត្ថន័យនៃឃ្លានីមួយៗរបស់ធម៌ជឿ ធ្វើឱ្យលោកកាន់តែមានភាពក្លាហាន និងមានជំនឿរឹងមាំជាងមុនដើម្បីបញ្ជូនបន្តជំនឿទៅកាន់ប្អូនៗនៅព្រះសហគមន៍របស់ខ្លួន។

ជាមួយគ្នានេះដែរ លោក ដួង សារ៉ង់ ប្រធានការិយាល័យអប់រំជំនឿ បានប្រសាសន៍ថា៖«តាមពិតធម៌ប្រកាសជំនឿ បើយើងសរសេរនៅក្នុងសៀវភៅមិនបានមួយទំព័រទេ ប៉ុន្តែធម៌ប្រកាសជំនឿជាប្រភពនៃជំនឿដែលបុព្វបុរសរបស់យើងបានសង្ខេបមកក្លាយជាធម៌ប្រកាសជំនឿ»។

លោកបានបន្តថា៖«ដូច្នេះពាក្យមួយម៉ាត់ៗនៃធម៌ប្រកាសជំនឿមានអត្ថន័យវែងឆ្ងាយ ហើយនៅក្នុងសិក្ខាសាលារបស់យើងនេះព្យាយាមយកមកចែកជូនដល់លោកគ្រូអ្នកគ្រូអប់រំជំនឿឱ្យកាន់តែយល់បន្ថែមទៀតដោយយើងពឹងផ្អែកលើគោលលិទ្ធិនៃជំនឿរបស់ព្រះសហគមន៍»។

លោក ដួង សារ៉ង់ ក៏បានបញ្ជាក់ដែរថា សិក្ខាសាលាគ្រូអប់រំជំនឿភាគទី២ ដែលនិយាយអំពី «ខ្ញុំជឿលើព្រះយេស៊ូគ្រីស្តជាព្រះបុត្រាតែមួយនៃព្រះបិតាហើយព្រះអម្ចាស់យើងខ្ញុំ» នឹងប្រព្រឹត្តទៅនៅចុងឆ្នាំ២០២៣នេះផងដែរ៕

# អភិបាលភូមិភាគបាត់ដំបង លោក អេនរីគេ ហ្វីការេដូ ទទួលពានរង្វាន់ «Gijónes of the Year»

*អត្ថបទ៖ ព្រះសហគមន៍*

អភិបាលប្រចាំព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង លោក អេនរីគេ ហ្វីការេដូ បានទទួលពានរង្វាន់ «Gijónes of the Year» នាទីក្រុង Gijón នៃប្រទេសអេស្ប៉ាញ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ កន្លងទៅនេះ ដែលនេះជាឆ្នាំដំបូងដែលលោកអភិបាល ទទួលពានរង្វាន់នេះ។

លោកអភិបាលអេនរីគេ ហ្វីការេដូ មានប្រសាសន៍នាពិធីនោះថា ៖ «ជាធម្មតា គេជ្រើសរើសយកអ្នកដែលពូកែខាងមុខជំនួញនានា និងខាងអង្គការនានា ប៉ុន្តែឆ្នាំនេះគេជ្រើសរើសយកខ្ញុំ ដូចជាស្ថានទូតប្រកាសដំណឹងល្អ អង្គការមនុស្សធម៌ និងខាងព្រះសហគមន៍ដើម្បីឱ្យក្នុងទីក្រុង Gijón ដឹងថា មានមនុស្សម្នាក់ដែលចេញពីទីក្រុងនោះធ្វើអំពើល្អ សម្រាប់អ្នកដទៃ ជាពិសេសសម្រាប់អ្នកក្រីក្រ»។

លោកអភិបាល បានបន្ថែមទៀតថា លោកពិតជាសប្បាយចិត្តណាស់ ដែលត្រូវបានគេទទួលស្គាល់ពីសកម្មភាពរបស់លោក ដែលមាននៅខេត្តបាត់ដំបង ខាងអង្គការមនុស្សធម៌ ខាងព្រះសហគមន៍ ដូចជាគំរូសម្រាប់ប្រជាជននៅទីក្រុង Gijónផងដែរ។

សូមបញ្ជាក់ផងដែរថា កម្មវិធីនេះត្រូវបានរៀបចំឡើងអស់រយៈពេល៧ឆ្នាំ ហើយដែលជាគំនិតផ្តួចផ្តើមដោយអភិបាលក្រុង Gijón លោកស្រី Carmen Moriyón។ កម្មវិធីនេះបង្កើតឡើងក្នុងគោលបំណងលើកទឹកចិត្តប្រជាពលរដ្ឋដែលបានរស់នៅ និងមានទីកំណើតនៅក្នុងទីក្រុង Gijón និងបានធ្វើកិច្ចការសប្បុរសធម៌ មនុស្សធម៌នានាដែលជាគំរូសម្រាប់ប្រជាជនរស់នៅក្នុងទីក្រុងនោះ៕





# កុមារាកុមារី១៧នាក់ទទួលអគ្គសញ្ញាទទួលព្រះកាយ

*អត្ថបទ៖ អាន គីមមួយ*

ព្រះសហគមន៍កាតូលិកបាត់ដំបង បានអបអរសាទរដល់កុមារាកុមារី ចំនួន ១៧នាក់ទទួលបានអគ្គសញ្ញាទទួលព្រះកាយ និងស្វាគមន៍បេក្ខជន១៩នាក់ទទួលជំហានទី១ កាលពីនៅថ្ងៃទី ៣០ ខែកក្កដា ឆ្នាំ២០២៣ ដោយមានលោកបូជាចារ្យម៉ានុច កុមារឯកា ជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍បាត់ដំបង ជាអធិបតី និងមានការចូលរួមពីសំណាក់លោកឧបដ្ឋាក ជួរ ដាម៉ូ ម៉ាតាំង បងស្រីបងប្អូនគ្រីស្តបរិស័ទជាច្រើនរូបទៀត។

ក្នុងធម្មទេសនា លោកឧបដ្ឋាកមានប្រសាសន៍ថា ៖ «ព្រះជាម្ចាស់បានប្រទានព្រះយេស៊ូ មកចាប់កំណើតជាមនុស្ស ដើម្បីមករំដោះបាប និងសង្គ្រោះយើង នៅពេលយើងបានទទួលព្រះកាយ គឺព្រះយេស៊ូបានចូលនៅក្នុងដួងចិត្តយើង ហើយយើងត្រូវស្រឡាញ់ ថែរក្សារាងកាយយើង ក៏ដូចជាស្រឡាញ់និងថែរក្សា រាងកាយអ្នកដទៃផងដែរ»។

លោកឧបដ្ឋាកបានបន្ថែមទៀតថា នៅពេលលោកបូជាចារ្យធ្វើសញ្ញាឈើឆ្កាង នៅលើរាងកាយបងប្អូន ប្រៀបបានដូចជាព្រះជាម្ចាស់ដៅសញ្ញាឈើឆ្កាងឱ្យរូបកាយ ពោរពេញដោយក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និងដើរតាមព្រះអង្គ។

ស្របពេលជាមួយគ្នានេះដែរ លោកបូជាចារ្យម៉ានុច កុមារឯកា ក៏បានថ្លែងនាឱកាសនោះដែរក្នុងពេលនេះ ព្រះសហគមន៍ព្រះជាម្ចាស់ លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ មានអំណរសប្បាយខ្លាំងណាស់ ដោយសារ [យើង] មានកម្មវិធីពីរ គឺ បងប្អូនស្ម័គ្រចិត្ត១៩នាក់ចូលរួមក្នុងព្រះសហគមន៍ ដែលនេះជាអំណោយទានរបស់ព្រះជាម្ចាស់ចំពោះបេក្ខទាំង១៩នាក់ ទទួលជំហានទី១ និងប្រកាសជំនឿរបស់ពួកគេ ហើយបង្ហាញអារម្មណ៍របស់ពួកគេទុកចិត្តលើព្រះជាម្ចាស់ទុកចិត្តលើព្រះសហគមន៍។



លោកមានប្រសាសន៍ថា ៖ «កូនចៅព្រះសហគមន៍បាត់ដំបងរីកចម្រើនឡើង និងមានចំនួនច្រើនឡើងដូចលោកតាអាប្រាហាំនេះជាទីសម្គាល់មួយសម្រាប់ព្រះសហគមន៍បាត់ដំបង។ មួយវិញទៀត ថ្ងៃនេះក៏មានកុមារាកុមារី១៧នាក់ទទួលអគ្គសញ្ញាទទួលព្រះកាយ ព្រះលោហិតព្រះគ្រីស្តលើកដំបូង ដែលនេះជាអំណោយទាន និងជាអំណរសប្បាយរបស់ក្មេងៗ ដែលប៉ុន្មានឆ្នាំត្រៀមចិត្តគំនិតដើម្បីទទួលព្រះកាយព្រះលោហិតរបស់ព្រះគ្រីស្ត និងពួកគេបានទទួលអគ្គសញ្ញាសម្រុះសម្រួល ដែលជាអគ្គសញ្ញាសេចក្តីស្រឡាញ់ពីព្រះជាម្ចាស់»។

លោកបូជាចារ្យ ម៉ានុច កុមារឯកា ថា មានកុមារាកុមារីខ្លះ បានស្រក់ទឹកភ្នែក ដែលនេះបង្ហាញថាព្រះជាម្ចាស់ស្រឡាញ់ គ្រប់គ្នា សរីរាង្គទាំងអស់គ្នា ជាព្រះវិហារតូចមួយ។

កុមារី អេលីសាបិត សំអាត ជីជី បានបង្ហាញពីចំណាប់អារម្មណ៍ថា ៖ «ថ្ងៃនេះខ្ញុំមានអំណរសប្បាយណាស់ ដោយបានទទួលព្រះកាយលើកដំបូង។ នៅពេលខ្ញុំបានទទួលព្រះកាយព្រះគ្រីស្ត គឺព្រះយេស៊ូគង់នៅក្នុងដួងចិត្តខ្ញុំ ហើយឱ្យខ្ញុំចេះស្រឡាញ់ខ្លួនឯង និងស្រឡាញ់អ្នកដទៃឱ្យដូចខ្លួនឯងដែរ។ ខ្ញុំប្តេជ្ញាចិត្តថា និងប្រព្រឹត្តកិច្ចការឱ្យសមនឹងបុត្រធីតារបស់ព្រះជាម្ចាស់ និងធ្វើជាគ្រីស្តបរិស័ទល្អក្នុងព្រះសហគមន៍»។

ចំណែក អ្នកស្រី វ៉ាន់ធី ជាបេក្ខជនទទួលជំហានទី១បានលើកឡើងដែរថា ៖ «ការផ្លាស់ប្តូរជំនឿរបស់ខ្ញុំ ដោយសារខ្ញុំឃើញពីគំរូដែលព្រះសហគមន៍មាន ដូចជា ការជួយអ្នកក្រីក្រ ចាស់ជរា និងផ្តល់ក្តីស្រឡាញ់ដល់បងប្អូនឯទៀត ដោយមិនប្រកាន់សាសនា ជនជាតិណាឡើយ ទើបខ្ញុំសម្រេចចិត្តចូលរួមជាសមាជិកថ្មីក្នុងព្រះសហគមន៍បាត់ដំបង»៕

# លោក គយ សារ៉ុម ចំណាយពេល២០ឆ្នាំសិក្សាអំពីព្រះសហគមន៍

*អត្ថបទ៖ កែវ កញ្ញា*







លោកគយ សារ៉ុម បានចំណាយពេលជាង ២០ឆ្នាំ ដើម្បីស្វែងរកព្រះពន្លឺរបស់ព្រះជាម្ចាស់ តាមរយៈកិច្ចការងារសិល្បៈរបស់គាត់ក្នុងព្រះសហគមន៍សន្តីម៉ារីញញឹម ក្នុងភូមិចំការទៀង ឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ នៅភាគខាងត្បូងនៃប្រទេសដែលមានចម្ងាយប្រមាណ៨០គីឡូម៉ែត្រពីរាជធានីភ្នំពេញ។

លោកគយសារ៉ុម អាយុ៦៧ឆ្នាំ បានប្រឡូកក្នុងវិស័យសិល្បៈនៅមន្ទីរវប្បធម៌ខេត្តតាកែវ ដោយចាប់យកជំនាញផ្នែកសិល្បៈបុរាណតាំងពីឆ្នាំ១៩៨០។ ក្នុងឆ្នាំ២០០២ លោកអូលីវីយេ ជ្មីតហាស្លេ ជាបូជាចារ្យទទួលខុសត្រូវតំបន់ បានអញ្ជើញលោក មកបង្ហាត់សិល្បៈដល់កុមារនិងយុវជននៅព្រះវិហារសន្តីម៉ារីញញឹមចំការទៀត រៀងរាល់ថ្ងៃសៅរ៍និងអាទិត្យ។

លោកសារ៉ុម បានខិតខំស្រាវជ្រាវអំពីព្រះគម្ពីរកាតូលិក ទោះបីជាលោកមិនមែនជាគ្រីស្តបរិស័ទក៏ដោយ ព្រោះលោកត្រូវសរសេររឿងជាច្រើន ឲ្យយុវជនសម្តែងក្នុងឱកាសបុណ្យនានា ជាពិសេសគឺបុណ្យព្រះយេស៊ូប្រសូត ដែលតែងតែសម្តែងចេញជារៀងរាល់ឆ្នាំក្នុងព្រះសហគមន៍ មានរឿងប្រស្នានានាក្នុងគម្ពីរ និងរបាំលើកតម្កើងព្រះជាម្ចាស់ជាដើម។

លោកគ្រូសិល្បៈរូបនេះឲ្យដឹងថា «ជាការលំបាកដែរ នៅពេលដែលចាប់ផ្តើមរឿងផ្នែកគ្រីស្តសាសនាដំបូងដោយសារខ្ញុំមានមូលដ្ឋានគ្រឹះពីព្រហ្មញ្ញសាសនានិងពុទ្ធសាសនា ហើយខ្លះៗក៏មានការលំបាកអំពីការប្រើពាក្យពេចន៍»។

លោកគ្រូវ័យចូលនិវត្តន៍ បន្ថែមថា «ប៉ុន្តែអ្វីដែលសំខាន់នោះគឺខ្ញុំបានអានព្រះគម្ពីរបស់គ្រីស្តសាសនាដើម្បី ដឹងអំពីមូលដ្ឋានគ្រឹះខ្លះៗ ហើយនៅពេលដែលខ្ញុំឆ្ងល់ឬក៏ទាក់នៅកន្លែងណាមួយ ខ្ញុំតែងតែអានព្រះគម្ពីរ ជាប្រចាំ ហើយក៏ពិភាក្សាជាមួយនឹងលោកអ៊ំសាមានជាប្រធានការិយាល័យសិល្បៈ និង សួរនាំលោកកុល ជាង អ្នកអប់រំជំនឿនៅក្នុងភូមិចំការទៀង ជាពិសេសទទួលបានពន្លឺពីលោកអភិបាលអូលីវីយេ»។

លោកសារ៉ុម បញ្ជាក់ថា «ខ្ញុំពេញចិត្តទៅនឹងពាក្យខ្លះដែលមានក្នុងព្រះគម្ពីរ ជាហេតុធ្វើឲ្យខ្ញុំចូលកាន់តែជ្រៅទៅៗ។ ពាក្យដែលខ្ញុំបានចងចាំនិងស្រឡាញ់គឺ អ្នកណាដែលមានអាវពីរ ផ្តល់ឱ្យអ្នកដែលអត់មួយ ឃើញថាយើងមានភាពស្មើគ្នា»។

ដោយបានយល់ដឹងអំពីព្រះគម្ពីរនិងសកម្មភាពរបស់ព្រះសហគមន៍ជាង២០ឆ្នាំមកនេះ សារ៉ុមក៏សម្រេចចិត្តទទួលពិធីជ្រមុជទឹកកាលពីខែមេសានារាត្រីបុណ្យចម្លងក្នុងឆ្នាំ២០២៣នេះ នៅព្រះវិហារសន្តីម៉ារីចំការទៀង ជាមួយបេក្ខជនដទៃទៀត។

នៅក្នុងប្រទេសកម្ពុជារដ្ឋធម្មនុញ្ញមាត្រា ៤៣បានចែងថា ប្រជាជនកម្ពុជាទាំងពីរភេទមានសេរីភាពខាងជំនឿនិងប្រណិប័តន៍ខាងផ្លូវសាសនា ហើយត្រូវបានរដ្ឋធានាក្នុងលក្ខខណ្ឌមិនប៉ះពាល់ដល់សាសនាដទៃ ឬសណ្តាប់ធ្នាប់និងសន្តិសុខសាធារណៈ។

បច្ចុប្បន្ន ប្រទេសក្នុងអនុតំបន់ទន្លេមេគង្គមួយនេះ មានសាសនិកភាគច្រើនកាន់ព្រះពុទ្ធសាសនាដែលមាន៩៥% អ៊ីស្លាមសាសនាចំនួន៣% គ្រីស្តសាសនា១%ដែលក្នុងនោះកាតូលិកមានចំនួន២ម៉ឺននាក់ និងសាសនាផ្សេងទៀត១%។

ទោះបីនៅពេលសារ៉ុមមិនទាន់ក្លាយជាគ្រីស្តបរិស័ទក៏ដោយ គាត់បានប្រណិប័តន៍ខ្លួន និងបង្ហាញជំនឿកាតូលិកដល់គ្រួសារ មិត្តភក្តិ និងអ្នកជិតខាងរបស់គាត់។ លោកនិយាយថា មិត្តភក្តិតែងនិយាយដល់គាត់ថា «សារ៉ុមគាត់ទៅខាងនោះហើយ(កាតូលិក) ចំណែកឯយើងនៅខាងពុទ្ធសាសនា ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំនៅតែមានទំនាក់ទំនងល្អជាមួយនឹងពួកគាត់»។

«គ្មាននរណាគេរើសអើងខ្ញុំទេ ពីព្រោះនៅក្នុងតំបន់ដែលខ្ញុំរស់នៅនោះគឺ ពួកគេគឺជាមនុស្សដែលសិក្សាមានចំណេះដឹងហើយមានមនុស្សតិចណាស់ដែលអវិជ្ជា» លោកសារ៉ុមបន្ថែម។

បច្ចុប្បន្នលោកសារ៉ុមរស់នៅក្នុងភូមិចុងថ្នល់ សង្កាត់បារាយ ក្រុងដូនកែវ ខេត្តតាកែវ មានកូនចំនួន៤នាក់ ដែល២នាក់នៅក្នុងបន្ទុក។

នៅពេលលោកសារ៉ុម ចូលរៀនអប់រំជំនឿ គាត់បានប្រាប់ដំណឹងនេះដល់កូនៗរបស់គាត់និងភរិយា។ «គាត់ធ្លាប់ប្រាប់ខ្ញុំតើ។ បើតាមខ្ញុំដឹងពីប៉ាខ្ញុំ (គ្រីស្តសាសនា)ជួយអប់រំបានច្រើនឲ្យដើរផ្លូវល្អ»។ នេះជាការបញ្ជាក់របស់គយ ធ្នូសារពណ៌ អាយុ១៥ឆ្នាំ រៀនថ្នាក់ទី១០ ដែលកំពុងរស់នៅជាមួយឪពុក។

ទោះបីជាឪពុកផ្លាស់ប្តូរជំនឿថ្មីក៏ដោយ យុវជនរូបនេះយល់ថា វាមិនប៉ះពាល់ដល់ទំនាក់ទំនងក្នុងគ្រួសារនោះឡើយ។ គាត់បន្លឺថា «ខ្ញុំគិតថាគ្រីស្តបរិស័ទគឺល្អ សាសនាណាក៏ល្អដែរ»។

នៅក្នុងព្រះសហគមន៍កាតូលិកនៅកម្ពុជាជារៀងរាល់ឆ្នាំមានអ្នកផ្លាស់ប្តូរជំនឿ ដោយទទួលអគ្គសញ្ញាជ្រមុជទឹកប្រមាណជា១៥០-២០០នាក់នៅក្នុងភូមិភាគទាំងបី។

លោកសារ៉ុមមានបំណងប្រើប្រាស់ទេពកោសល្យរបស់លោកក្នុងវិស័យសិល្បៈនេះ និងការយល់អំពីព្រះគម្ពីរដើម្បីប្រកាសផ្សាយដំណឹងល្អអំពីព្រះយេស៊ូនៅក្នុងប្រទេសកម្ពុជា។ លោកនិយាយថា «ខ្ញុំត្រូវសិក្សាអំពីព្រះគម្ពីរបណ្តើរៗទៀតដើម្បីក្លាយទៅជាមូលដ្ឋានទៅក្នុងការអប់រំជំនឿបន្ត ហើយខ្ញុំក៏មានបំណងចង់ឲ្យកូនៗនិងប្រពន្ធរបស់ខ្ញុំក្លាយទៅជាគ្រីស្តបរិស័ទដូចគ្នាផងដែរ»។

ដំណាក់កាលអប់រំជំនឿរបស់ព្រះសហគមន៍កាតូលិកនៅកម្ពុជា

ជាទូទៅក្នុងដំណាក់កាលអប់រំជំនឿរបស់ព្រះសហគមន៍កាតូលិក មានរយៈពេល១ឆ្នាំឡើងទៅ។ ការរៀននេះ តម្រូវឲ្យបុគ្គលទាំងអស់ចំណាយពេល១ម៉ោងក្នុងមួយសប្តាហ៍ជារៀងរាល់ថ្ងៃអាទិត្យ។ ហើយបេក្ខជនទាំងអស់ត្រូវមានដំណាក់កាលចំនួន ២ គឺពិធីសុំចូលព្រះសហគមន៍ និងពិធីត្រាស់ហៅយ៉ាងឱឡារិកពីលោកអភិបាលភូមិភាគនីមួយៗ។

លោកដួង សារង់ ប្រធានការិយាល័យអប់រំជំនឿភូមិភាគភ្នំពេញមានប្រសាសន៍ថា បុគ្គលម្នាក់ដែលចង់ផ្លាស់ប្តូរជំនឿមកកាតូលិក គឺត្រូវមានអាយុ១៨ឆ្នាំឡើងទៅនៅពេលទទួលអគ្គសញ្ញាជ្រមុជទឹក បើអាយុក្រោមនេះ ត្រូវមានលិខិតអនុញ្ញាតពីអាណាព្យាបាល។

លោកប្រធានការិយាល័យរូបនេះបន្តទៀតថា ក្នុងដំណាក់កាលបញ្ចប់ បេក្ខជនត្រៀមខ្លួនត្រូវរៀបចំចិត្តគំនិតរយៈពេល៤០ថ្ងៃទៀតមុនជ្រមុជទឹក គឺមានការជំរះចិត្តចំនួន៣ដង ដែលជួយបន្ថែមលើសេចក្តីបង្រៀនទាំងប៉ុន្មានកន្លងមក និងរិះគិតស៊ីជម្រៅលើជំនឿនិងចិត្តគំនិត ដើម្បីក្លាយជាមនុស្សថ្មី។ ជាមួយគ្នានេះដែរ ពួកគាត់ក៏នឹងទទួលធម៌ប្រកាសជំនឿ និងធម៌ឱព្រះបិតា។

លោកសារង់បន្ថែមថា ការអប់រំរបស់យើងគឺឲ្យស្លាប់ភាពអាត្មានិយមដែលសង្គមទូទៅតែងមានឲ្យស្លាប់ក្នុងពេលជ្រមុជក្នុងទឹក ហើយរស់ឡើងវិញចូលទៅក្នុងជីវិតថ្មីតាមរបៀបព្រះយេស៊ូ គឺរស់ឡើងវិញដោយគ្មានភាពអាត្មានិយម និងរស់នៅក្នុងព្រះជន្មរបស់ព្រះជាម្ចាស់។

ព្រះសហគមន៍នៅក្នុងភូមិភាគភ្នំពេញ បានកំណត់ថា ក្នុងពិធីជ្រមុជទឹក សម្រាប់បេក្ខជនទាំងអស់គឺអាចទទួលបានអគ្គសញ្ញាចំនួន២គឺ ជ្រមុជទឹក និងព្រះកាយនិងព្រះលោហិតព្រះគ្រីស្ត ដែលនៅពេលនេះ គេឲ្យហៅពួកគាត់ថា «ក្រុមពន្លកថ្មី» រីឯលាបថ្ងាស ត្រូវលើកទៅរយៈពេល១ឆ្នាំក្រោយ ក្នុងបុណ្យព្រះវិញ្ញាណយាងមក។ ដំណាក់កាលនៃការអប់រំសម្រាប់ក្រុមនេះគឺត្រូវមានជាបន្តទៀតរហូតដល់រដូវរង់ចាំ ដែលត្រូវរៀនអំពីអគ្គញ្ញាលើកលែងទោស ដើម្បីឲ្យជីវិតអាចចូលរួមក្នុងកំណើតព្រះយេស៊ូ។

ព្រះសហគមន៍មានអគ្គសញ្ញាចំនួន៧ ដែលក្នុងនោះរួមមាន ជ្រមុជទឹក អរព្រះគុណ(ព្រះកាយនិងព្រះលោកហិត) លាបថ្ងាស លើកលែងទោស អាពាហ៍ពិពាហ៍ តែងតាំង និងលាបប្រេងផ្តល់កម្លាំង៕



# យុវជនកម្ពុជា ចូលរួមទិវាយុវជនពិភពលោកនៅព័រទុយហ្គាល់





ការចូលរួមទិវាយុវជនពិភពលោកដែលបានធ្វើឡើងនៅទីក្រុងលីសបោន នៃប្រទេសព័រទុយហ្គាល់ បានបញ្ចប់ទៅដោយផ្លែផ្កា និងពោរពេញដោយភាពស្រស់ស្អាត និងបទពិសោធសម្រាប់យុវជនគ្រីស្តបរិស័ទ ដែលមានប្រមាណ១៩០ប្រទេសបានចូលរួម។

ខណៈពេលត្រឡប់ពីលីសបោន យាងទៅទីក្រុងរ៉ូមវិញ សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ បានប្រាប់អ្នកសារព័ត៌មានថា ទ្រង់ពិតជារីករាយ ចំពោះវត្តមាន និងការអបអរដោយក្រុមយុវជនជាច្រើននៅលីស្បោន ។

សម្តេចប៉ាបបានមានបន្ទូលថា ទិវាយុវជនលើកនេះ គឺល្អបំផុតតាំងពីទ្រង់បានយាងចូលរួម នៅទីក្រុងរីយ៉ូដឺ ចេនណេរ៉ូ (Rio de Janeiro)នៅប្រេស៊ីល ទីក្រុងក្រាកូវ និង ប៉ាណាម៉ា ។

ព្រះសហគមន៍នៅប្រទេសកម្ពុជា មានយុវជន បព្ជិត-ជិតា និងលោកអភិបាល សរុប៤៥នាក់ បានទៅចូលរួមផងដែរ កាលពីថ្ងៃទី២៥ ខែកក្កដា ដល់ថ្ងៃទី៨ ខែសីហាកន្លងទៅ។

មិនមែនមានតែព្រះសហគមន៍យើងតូចដែលមកចូលរួមក្នុងកម្មវិធីនេះប៉ុណ្ណោះ គឺមានបងប្អូនជាច្រើនមកពីគ្រប់ប្រទេស គ្រប់ជាតិសាសន៍ទាំងអស់។ អូន សុភីម អាយុ២១ឆ្នាំពីព្រះវិហារសន្តីម៉ារីញញឹមចំការទៀង ឲ្យដឹងទៀតថា «កម្មវិធីនេះ ខ្ញុំបានបទពិសោធខ្លះៗដូចជាសិក្ខាសាលា អធិដ្ឋាន ចែកបទពិសោធ ទោះបីពេលខ្លះខ្ញុំស្តាប់ភាសាគេមិនបាន។»

សុភីម បន្តថា បងប្អូនទាំងអស់គ្នាគឺរួសរាយរាក់ទាក់មិនថា ជនជាតិណាទេ គឺស្វាគមន៍និងមានស្នាមញញឹមជានិច្ចចំពោះគ្នា មិនរើសអើង ហើយយកចិត្តទុកដាក់ចំពោះគ្នា។ «អ្វីដែលខ្ញុំទទួលបានខ្លាំងបំផុតនៅទីនេះ គឺក្តីស្រឡាញ់ និងធម៌មេត្តាករុណាចំពោះខ្ញុំគឺឥតមានអីនឹងថ្លែងបាន ទោះបីពេលខ្លះយើងធ្វើដំណើរហត់ អស់កម្លាំង ប៉ុន្តែពួកយើងនៅមានកម្លាំងនិងស្នាមញញឹមខ្លាំងបំផុត ដើម្បីឆ្ពោះទៅមុខ។»

ង៉ិន ចាន់ណា ជាបុគ្គលិកការិយាល័យយុវជនភូមិភាគភ្នំពេញបាននិយាយថា

យើងមកពីប្រទេសផ្សេងៗ យើងអាចទំនាក់ទំនងគ្នាបាន ដោយប្រើភាសាបេះដូងនិងដោយកាយវិការខ្លះ ទោះយើងខ្សោយភាសាពិតមែន។ ម្យ៉ាងវិញទៀតការរៀបចំកម្មវិធីនីមួយៗបានល្អប្រសើរ ដើម្បីយើងទទួលអំណរសប្បាយក្នុងកម្មវិធីទាំងមូល។

ចាន់ណាបន្តថា ព័រទុយហ្គាល់ជាប្រទេសដែលមានចំណាស់មួយផ្នែកជំនឿគ្រីស្តសាសនា។ «ខ្ញុំឃើញថានៅខាងក្រៅពួកគាត់លេងសើចសប្បាយ តែពេលចូលអធិដ្ឋាននិងអភិបូជា គឺពួកគាត់ផ្តោតអារម្មណ៍ខ្លាំងមែនទែនជាមួយព្រះជាម្ចាស់។ នេះជាគំរូមួយដែលយើងទទួលបាន។»

ដំណើរទៅកាន់ទិវាយុវជនពិភពលោកលើកនេះ





គណៈប្រតិភូកម្ពុជាបានចំណាយពេល២សប្តាហ៍នៅទីក្រុងប័រទុយម៉ៅនៃប្រទេសព័រទុយហ្គាល់ ដោយបានប្រជុំ សិក្ខាសាលា និងអធិដ្ឋានជាមួយយុវជននៃប្រទេសផ្សេងៗទៀតជាច្រើន ដោយសិក្សាឈ្វេងយល់ជាមួយជំនឿ ការត្រាស់ហៅ និងការរស់នៅរបស់ប្រជាជនក្នុងតំបន់។

ថ្ងៃបន្ទាប់មកក្រុមយុវជននេះ បានទៅព្រះវិហារសន្តអង់ទន់ ដំណាក់សន្តគ្រួស (Cruz) និងទីសក្ការដ្ឋានព្រះនាងម៉ារីបង្ហាញខ្លួនឲ្យគង្វាលនៅហ្វាទីម៉ា និងទទួលការណែនាំពីលោកអភិបាលអូលីវីយេ ជ្មីតហាស្លេ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញនៅព្រះវិហារសន្តយ៉ាកុបនាពេលព្រឹកក្នុងរយៈពេល៣ថ្ងៃ គឺនៅថ្ងៃទី២-៤ ខែសីហា លើប្រធានបទ «ព្រះនាងម៉ារីក្រោកឡើងប្រញាប់ប្រញាល់»។

នៅថ្ងៃទី១នៃការរិះគិត លោកអភិបាលអូលីវីយេ បានណែនាំក្រុមយុវជនកម្ពុជា ឲ្យមានទំនាក់ទំនងជាមួយភពផែនដីដែលជាផ្ទះរួម ដូចព្រះត្រៃឯកដោយផ្សារភ្ជាប់ជាមួយសេចក្តីស្រឡាញ់ ដែលក្នុងនោះមាន៤ចំណុចសំខាន់ៗ គឺទី១ គឺទំនាក់ទំនងជាមួយព្រះម្ចាស់ ដែលជាប្រភពនៃជីវិត ដែលនាំអោយយើងដឹងថា ព្រះជាម្ចាស់បានបង្កើតយើង បង្កើតបងប្អូនឯទៀតៗ និងបរិស្ថាន។ ទី២ ទំនាក់ទំនងជាមួយបងប្អូនដោយសេចក្តី គឺយើងត្រូវស្រឡាញ់ដើម្បីជួយគេឱ្យរីកចម្រើនក្នុងគ្រប់វិស័យ។

ទី៣ ទំនាក់ទំនងជាមួយខ្លួនឯង គឺការស្រឡាញ់ខ្លួនឯង ដែលនាំឱ្យយើងស្រលាញ់បងប្អូនឯទៀត និងបរិស្ថានដែរ។ ការស្រឡាញ់ខ្លួនឯងគឺគ្មានអាត្មានិយម តែត្រូវចេះរៀបចំខ្លួនមានអនាម័យ ខិតខំរៀនសូត្រឱ្យមានចំណេះជាដើម ដើម្បីជួយខ្លួនឯងនិងអ្នកដទៃ។ និងទី៤ ទំនាក់ទំនងជាមួយបរិស្ថានធម្មជាតិ ដែលនៅជុំវិញខ្លួនយើង។ យើងត្រូវដឹងថា យើងមិនអាចរស់ដោយគ្មានធម្មជាតិបានឡើយ ប៉ុន្តែធម្មជាតិអាចរស់ដោយគ្មានយើងបាន។

នៅថ្ងៃទី២លោកអភិបាលលោកអភិបាលបានជំរុញឲ្យយើងស្រឡាញ់ដូចព្រះយេស៊ូបានស្រឡាញ់មនុស្សលោក គឺសហកាគ្នាដើម្បីគិតនិងបង្កើតផលប្រយោជន៍រួម ដោយមើលឃើញសេចក្តីត្រូវការរបស់បុគ្គលម្នាក់ៗដែលយើងបានជួប មិនថាក្នុងគ្រួសារ ព្រះសហគមន៍ និងសង្គម ដោយយកចិត្តទុកដាក់លើតម្លៃនៃជីវិត តាំងពីកើតរហូតដល់ស្លាប់។

លោកអភិបាលបន្ថែមថា កុំធ្វើអ្វីដោយពឹងលើអារម្មណ៍ ឬនិស្ស័យរបស់ខ្លួនតែប៉ុណ្ណឹង «តែយើងត្រូវមានចិត្តដូចព្រះជាម្ចាស់ជាព្រះបិតា»។

លោកអភិបាលបង្រៀនទៀតថា ការបើកចិត្តគំនិត គឺបើកចំណេះដឹងឆ្ពោះទៅរកគ្រប់វប្បធម៌នានា នាំឲ្យយើងលែងរស់នៅក្នុងសង្គមជាតិនិយម ព្រោះយើងត្រូវទីពឹងលើគ្នាទៅវិញទៅមក ដើម្បីឱ្យសង្គមរីកចម្រើន និងខ្លួនរីកចម្រើន។

រីឯថ្ងៃទី៣ លោកអភិបាលអូលីវីយេ បានណែនាំអំពីផ្លូវជីវិត គិតពិចារណា និងស្គាល់ខ្លួនឯង។ ក្នុងនោះផ្លូវជីវិតមាន៣សម្រាប់យុវជនគ្រីស្តបរិស័ទគឺ បង្កើតគ្រួសារ នៅលីវ និងចូលរួមក្រុមអ្នកបួស។

ក្នុងដំណើរជីវិតរបស់យើងគឺត្រូវមានសសរ៣ គឺទី១ ជំនឿលើព្រះជាម្ចាស់ ដែលណែនាំអោយមានប្រាជ្ញាឈ្លាសវៃ ចាស់ទុំ មានទំនួលខុសត្រូវ យល់ដឹង និងមើលឃើញទៅតាមបទពិសោធ ដើម្បីចូលជ្រៅក្នុងជំនឿនេះ។ ទី២ ទំនាក់ទនងក្នុងមេត្តាករុណាដែលនាំអោយយើងស្រលាញ់បងប្អូនឯទៀត។ ទី៣ អត្តសញ្ញាណរបស់គ្រីស្តបរិស័ទគឺក្តីសង្ឃឹម ទោះជីវិតពោរពេញដោយឧបសគ្គ និងទុក្ខលំបាក ប៉ុន្តែយើងមានពន្លឺរបស់ព្រះជាម្ចាស់នាំឲ្យយើងមិនអាចទៅមុខ។








សសរទាំងបីនេះ នាំឲ្យយើងអាចកសាងព្រះរាជ្យរបស់ព្រះជាម្ចាស់ក្នុងពិភពលោកនេះ ដោយបង្កើតផែនដីថ្មី ផ្ទៃមេឃថ្មី។ យុវជនត្រូវថែរក្សាពន្លឺរបស់យើង ដើម្បីស្គាល់ខ្លួនឯង និងសមត្ថភាពរបស់ខ្លួន ហើយត្រូវចូលក្នុងបទពិសោធផ្ទាល់ខ្លួន ដើម្បីទ្រាំទ្រជាមួយបញ្ហា

តស៊ូក្នុងជីវិតរបស់ដើម្បីទៅដល់គោលដៅ។

ជាមួយគ្នានោះ ក្រុមយុវជនក៏បានទៅទីលានParque Eduardo ដើម្បីទទួលសម្តេចប៉ាបហ្វ្រង់ស៊ីស្វ និងថ្ងៃបន្ទាប់អធិដ្ឋានផ្លូវឈើឆ្កាងជាមួយសម្តេចប៉ាបថ្ងៃបន្ទាប់បានធ្វើដំណើរចេញទៅទីលាន Campo Dagraca ដើម្បីអធិដ្ឋានតាំងព្រះកាយពេញមួយយប់ និងអភិបូជាបិទជាមួយសម្តេចប៉ាបនៅទីនោះ។

«ខ្ញុំចាប់អារម្មណ៍មែនទែនអំពីសម្តេចប៉ាបហ្វ្រង់ស៊ីស្វ ទោះបីគាត់ជិះរទេះដូចមនុស្សចាស់អាយុច្រើន (តែ)មានកម្លាំងដើម្បីលើកទឹកចិត្តយើងនាំឲ្យយើងមានកម្លាំង។» លោកអភិបាលអេនរីគេ ហ្វិការេដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង មានប្រសាសន៍ក្រោយជំនួបយុវជនជាមួយសម្តេចប៉ាបកាលពីថ្ងៃទី៤ សីហា។

លោកអភិបាលអេនរីគេ បន្ថែមថា សម្តេចប៉ាប ចង់ឱ្យយើងម្នាក់ៗនិងព្រះសហគមន៍ធ្វើជាពន្លឺសម្រាប់ណែនាំសេចក្តីសង្ឃឹម ឲ្យយើងណែនាំសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ឱ្យមនុស្សលោកស្គាល់ ហើយនេះបានលើកទឹកចិត្តយើងឱ្យស្រលាញ់ព្រះជាម្ចាស់ ស្រលាញ់ព្រះអំណោយទានដែលយើងទទួល។

សូមឲ្យយើងរួមគ្នា ជាមួយសម្តេចប៉ាបឱ្យមានចិត្តទូលាយនិងបង្ហាញធម៌មេត្តាករុណាដែលជាពន្លឺពីព្រះជាម្ចាស់សម្រាប់យើងទាំងអស់គ្នា។

លោកអភិបាលសិលា សួន ហង្សលី អភិបាលព្រះសហគមន៍ភូមិភាគកំពង់ចាម មានប្រសាសន៍ថា យុវជនទាំងអស់មានអំណរសប្បាយមែនទែន ដោយគេខិតខំប្រឹងប្រែងឱ្យអស់ពីសមត្ថភាពបង្កើតទំនាក់ទំនងជាមួយបងប្អូនៗទៀតហើយទទួលបានបទពិសោធន៍ថ្មីៗពីយុវជន នឹងអំពីអ្នកដែលផ្តល់សក្ខីភាពដែលយើងបានជួបតាំងពីប៉័ទុយម៉ៅរហូតមកដល់លីសបោននេះ។

លោកបានបន្តលើកឡើងបន្ថែមថា ពិតមែនយើងរស់នៅក្នុងពិភពលោកដែលមានទុក្ខលំបាកច្រើន យើងមានបញ្ហាសង្គ្រាម ឈ្លោះប្រកែកគ្នាវិបត្តិសេដ្ឋកិច្ចផ្សេងៗ ប៉ុន្តែយើងឃើញកម្លាំងនៃបងប្អូនយើងដែលចូលរួម ដោយសារមានវត្តមានសម្តេចប៉ាបយាងមកជាមួយយើងមានកម្លាំងមួយពិសេសដើម្បីឲ្យយើងម្នាក់ៗរួមគ្នាធ្វើបន្តិចម្តងៗ យើងអាចកែប្រែពិភពលោកយើងបានកាន់ល្អប្រសើរ។

លោកអភិបាលហង្សលីឲ្យដឹងទៀតថា សម្តេចប៉ាបបានដាស់តឿនយើងឱ្យទទួលសេចក្តីស្រលាញ់ពីព្រះជាម្ចាស់ដែលជាកម្លាំងសម្រាប់យើង ឱ្យយើងទាំងអស់គ្នាកុំឱ្យបាត់សេចក្តីសង្ឃឹម ឱ្យយើងទាំងអស់គ្នាយកសេចក្តីស្រលាញ់ទៅចែករំលែកដល់បងប្អូនឯទៀតៗ និងសូមឱ្យសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់នេះហូរតាមរយៈយើងទៅដល់បងប្អូនឯទៀតៗ។

លោកអភិបាលបន្ថែមថា «ខ្ញុំសង្ឃឹមបងប្អូននឹងយកបទពិសោធនេះទៅចែករំលែកដល់បងប្អូននៅក្នុងប្រទេសកម្ពុជា។»

លោកអភិបាលអូលីវីយេ ឲ្យដឹងទៀតថា ចាប់ពីថ្ងៃនេះតទៅ យើងបន្តជាមួយយុវជននៅក្នុងពិភពលោកដោយផ្លូវឈើឆ្កាងផង ដោយអធិដ្ឋានពេញមួយយប់ និងដោយមានអភិបូជាបិទ។ ប៉ុន្តែមិនមែនបិទជីវិតរបស់យើង ប៉ុន្តែផ្ទុយទៅវិញ អភិបូជាថ្ងៃអាទិត្យជាមួយសម្តេចប៉ាប គឺនាំឲ្យយើងចេញទៅ ដើម្បីប្រកាសដំណឹងល្អ ដើម្បីផ្តល់សក្ខីភាពអំពីជីវិតរបស់យើងជាគ្រីស្តបរិស័ទ និងដោយដឹងថា យើងជាគ្រីស្តបរិស័ទខ្មែរមួយរូប តើយើងធ្វើដូចម្តេចដើម្បីរស់នៅក្នុងបច្ចុប្បន្ននេះ ដោយថែរក្សានិងការពារអត្តសញ្ញាណរបស់យើងជាខ្មែរផង ជាគ្រីស្តបរិស័ទផង។

ទិវាយុវជនពិភពលោកលើកនេះមានយុវជនចូលរួមប្រមាណ១លាន៥សែននាក់ ដែលមកពីជាង១៩០ប្រទេស។ គេក៏សង្កេតឃើញថា ក្នុងទិវាមិនមែនមានតែគ្រីស្តបរិស័ទកាតូលិកចូលរួមប៉ុណ្ណោះ ក្នុងនោះក៏មានយុវជនជាច្រើននិកាយទៀតចូលរួមផងដែរ។

ទិវាយុវជនពិភពលោកលើកទី៣៨នឹងប្រព្រឹត្តទៅនៅឆ្នាំ២០២៧នៅឯប្រទេសកូរ៉េខាងត្បូង៕

*ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក*



## គោរពជូនពរ និងអបអរសាទរជូនចំពោះ
## ឯកឧត្តម កិត្តិទេសាភិបាលបណ្ឌិត

# ហ៊ុន ម៉ាណែត

## ដែលត្រូវបានព្រះមហាក្សត្រ ត្រាស់បង្គាប់តែងតាំងជា
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

យើងខ្ញុំ **អូលីវីយេ ឆ្មីតហស្លេ** ជាអភិបាលព្រះសហគមន៍កាតូលិក ភូមិភាគភ្នំពេញ
រួមជាមួយលោកអភិបាល ព្រះសហគមន៍ភូមិភាគបាត់ដំបង និងភូមិភាគកំពង់ចាម
អស់លោកបូជាចារ្យ បព្វជិត បព្វជិតាព្រមទាំង គ្រីស្តបរិស័ទទាំងអស់។

សូមឆ្លៀតក្នុងឱកាសដ៏ប្រពៃថ្លៃថ្លានេះ សូមគោរពជូនពរ និង អបអរសាទរ **ឯកឧត្តម កិត្តិទេសាភិបាលបណ្ឌិត នាយករដ្ឋមន្ត្រី**
សូមមានសុខភាពល្អ បរិបូរណ៍ កម្លាំងពលំមាំមួន ប្រាជ្ញាឈ្លាសវៃភ្លឺថ្លា ជន្មាយុយឺនយូរ ជោគជ័យ គ្រប់ភារកិច្ច និងឈ្នះអស់មារសត្រូវគ្រប់ទិសទី
ដើម្បីដឹកនាំរាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៧នៃរដ្ឋសភាទទួលបាននូវសមិទ្ធផលជូនជាតិមាតុភូមិ និងរីកចម្រើនបន្ថែមទៀត។

សូម **ឯកឧត្តម កិត្តិទេសាភិបាលបណ្ឌិត នាយករដ្ឋមន្ត្រី** និងក្រុមគ្រួសារជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។
ក្នុងនាមព្រះគ្រីស្ត យើងខ្ញុំ ជាអភិបាល បូជាចារ្យ បព្វជិត បព្វជិតា រួមជាមួយគ្រីស្តបរិស័ទនៃព្រះសហគមន៍ កាតូលិក
ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា សូមជូននូវព្រះពរសព្វសាធុការដល់ **ឯកឧត្តម កិត្តិទេសាភិបាលបណ្ឌិត នាយករដ្ឋមន្ត្រី**
និងក្រុមគ្រួសារ ទទួលបានសុខភាពល្អបរិបូរណ៍ កម្លាំងមាំមួន បញ្ញាញាណវាងវៃ អាយុយឺនយូរ ដើម្បីដឹកនាំ និងគ្រប់គ្រង ប្រទេសកម្ពុជា
ឈានដល់ការរីកចំរើន និង និងសេចក្ដីសុខក្សេមក្សាន្តបន្តទៅមុខទៀតដល់ប្រជាជនកម្ពុជាទាំងអស់គ្នា ។
សូម **ឯកឧត្តម កិត្តិទេសាភិបាលបណ្ឌិត នាយករដ្ឋមន្ត្រី** មេត្តទទួលនូវគារវភក្តីដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

CARITAS CHRISTI URGET NOS

**ព្រះសហគមន៍កាតូលិកនៅព្រះរាជាណាចក្រកម្ពុជា**

ថ្ងៃអង្គារ ១៤រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៣
ឯកឧត្តម អភិបាលព្រះសហគមន៍កាតូលិកនៅព្រះរាជាណាចក្រកម្ពុជា ភូមិភាគភ្នំពេញ

**អូលីវីយេ ឆ្មីតហស្លេ**